ជំពូកទី៦៖ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

៦.១ សេចក្តីផ្តើម

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូងនេះ គឺជាការសិក្សាដើម្បីកំណត់មើលហេតុផលនៃការប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមដំបូង ក្នុងរាល់ដំណាក់កាលនីមួយៗដូចជា ដំណាក់កាលរចនាគម្រោង (Project Design) ដំណាក់កាលសាងសង់ (Project Construction) និង ដំណាក់កាលប្រតិបត្តិគម្រោង (Project Operation)។ រាល់ហេតុប៉ះពាល់អវិជ្ជមានត្រូវរិះរកវិធានការកាត់បន្ថយយ៉ាងណាឱ្យដល់កម្រិតអប្បបរមា និងធ្វើផែនការគ្រប់គ្រងបរិស្ថាន នៃដំណាក់កាលទាំងនោះដោយមានការអនុវត្តពីម្ចាស់គម្រោង និងរួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័នជំនាញដែលពាក់ព័ន្ធក្នុងមូលដ្ឋាន និងដោយមានការត្រួតពិនិត្យពីក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធនានា។

ក្នុងការវាយតម្លៃនេះក្រុមការងារបានជ្រើសរើសយកតារាងបញ្ជីផ្ទៀងផ្ទាត់ (Checklist) និងតារាងម៉ាទ្រីក (Matrix) ដើម្បីកំណត់ទំហំនៃការប៉ះពាល់បរិស្ថានអវិជ្ជមានណាមួយដែលមានកម្រិតតិច មធ្យម និងខ្លាំងមកធ្វើការវិភាគ ព្រមទាំងរៀបចំវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនោះឱ្យដល់កម្រិតអប្បបរមា។

៦.២ វិធីសាស្ត្រ

វិធីសាស្ត្រសម្រាប់ប្រើនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម គឺអាចប្រែប្រួលទៅតាមប្រភេទគម្រោងនីមួយៗ និងផ្អែកទៅលើបទពិសោធន៍ ឬទៅលើឯកសារដែលមានស្រាប់ (Existing literatures or past experiences) ចំពោះគម្រោងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ វិធីសាស្ត្រដែលគេធ្លាប់ប្រើជាញឹកញាប់រួមមាន វិធីសាស្ត្រតាមបញ្ជីផ្ទៀងផ្ទាត់ វិធីសាស្ត្រម៉ាទ្រីក និងការប្រើប្រាស់សេចក្តីណែនាំដែលមានស្រាប់។

៦.២.១ វិធីសាស្ត្រតាមបញ្ជីផ្ទៀងផ្ទាត់ (Checklist)

វិធីសាស្ត្រនេះគឺជាបញ្ជីស្តង់ដារនៃប្រភេទហេតុប៉ះពាល់ ដែលទាក់ទងទៅនឹងប្រភេទនៃគម្រោងមួយជាក់លាក់ (Impact associated with a particular type of project)។ វិធីសាស្ត្រដោយប្រើបញ្ជីផ្ទៀងផ្ទាត់នេះ ត្រូវគេប្រើជាចម្បងសម្រាប់រៀបចំព័ត៌មាន(Organizing information) ឬក៏ធានាឱ្យបានថាហេតុប៉ះពាល់នានា (វិជ្ជមាន និងអវិជ្ជមាន) ដែលអាចកើតមានឡើងត្រូវបានលើក

Draft

ឡើង។ ចំពោះបញ្ជីផ្ទៀងផ្ទាត់នេះគេក៏អាចប្រើបញ្ជីផ្ទៀងផ្ទាត់ដែលមានលក្ខណៈសាមញ្ញ (Simple Checklist) ដែលជាបញ្ជីកំណត់នូវប៉ារ៉ាម៉ែត្របរិស្ថានដោយមិនទាមទារឱ្យមានការប្រើគោលការណ៍ណែនាំ (Guideline) ថាតើប៉ារ៉ាម៉ែត្រទាំងនោះត្រូវបានវាស់យ៉ាងដូចម្តេចឡើយ?

៦.២.២ វិធីសាស្ត្រម៉ាទ្រីក (Matrix Methods)

នេះគឺជាម៉ាទ្រីកសម្រាប់កំណត់ភាពប្រទាក់គ្នា រវាងសកម្មភាពនានារបស់គម្រោងទៅនឹងហេតុប៉ះពាល់នៃសមាសធាតុបរិស្ថានដែលអាចកើតមាន។ ម៉ាទ្រីកដែលមានភាពងាយស្រួលហើយដែលគេនិយមប្រើគឺម៉ាទ្រីក Phoenic Pulp Mill ឬ Leopold Matrix ដែលបង្ហាញអំពីភាពប្រទាក់គ្នារវាងសមាសភាគបរិស្ថាន (Environmental components) ជាមួយនឹងសកម្មភាពនានារបស់គម្រោង។

៦.២.៣ ប្រើប្រាស់សេចក្តីណែនាំតាមវិស័យដែលមានស្រាប់ (Sectorial guideline)

ការវាយតម្លៃហេតុប៉ះពាល់នៃបរិស្ថានត្រូវផ្អែកទៅលើឯកសារ ឬសេចក្តីណែនាំដែលមានស្រាប់ ព្រោះវាជួយបង្កើនល្បឿននៃការសិក្សាដោយផ្អែកលើបទពិសោធន៍ និងមេរៀនដែលទទួលបានចំពោះគម្រោងដែលមានលក្ខណៈស្រដៀងគ្នា ឧទាហរណ៍ដូចជាគោលការណ៍ណែនាំដែលបានបង្កើតឡើងដោយក្រសួងបរិស្ថាននៅឆ្នាំ២០០៩។

៦.៣ ការកំណត់អត្តសញ្ញាណនៃហេតុប៉ះពាល់បរិស្ថាន

ស្ថានភាពជាក់ស្តែងនៅក្នុងតំបន់គម្រោង និងសកម្មភាពរបស់គម្រោង បានបង្ហាញពីអត្តសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានទៅលើគម្រោងតាមដំណាក់កាលនីមួយៗ ដែលមានឥទ្ធិពលជាវិជ្ជមាន អវិជ្ជមាន និងគ្មានឥទ្ធិពលទៅលើធនធានវប្បសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៦.១៖ តារាងម៉ាទ្រីកសម្រាប់កំណត់អត្តសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោង

			ហេតុប៉ះពាល់អវិជ្ជមាន									ហេតុប៉ះពាល់វិជ្ជមាន			
			ដំណាក់កាលសាងសង់						ដំណាក់កាលប្រតិបត្តិ			ដំណាក់កាលសាងសង់		ដំណាក់កាលប្រតិបត្តិ	
			ចំណាត់ថ្នាក់ទូទៅ	ចុះធ្វើការសិក្សាជ្រើសរើសតន្លងខ្សែ	ការចល័តគ្រឿងចក្រសាងសង់	ការហូរចូលកម្ទេចសំណង់ និងការបង្កើតកន្លែងស្នាក់នៅបណ្តោះអាសន្ន	ការសាងសង់ផ្លូវចូល និងបង្គោល (ការឈូសឆាយ តម្លើងបង្គោល)			ការថែរក្សានិងជួសជុល	ការរំខានដោយរស្មីកក្រឹស្តាទឹក និង រស្មីកក្រឹម៉ាញ្ចេទិក		ការហូរចូលកម្ទេចសំណង់ និងការបង្កើតកន្លែងស្នាក់នៅបណ្តោះអាសន្ន	ជំរុញសេដ្ឋកិច្ចតាមភូមិ និងសេដ្ឋកិច្ចមូលដ្ឋាន (ការលក់ដូរ)	ការផ្តល់ផ្ទះបរិវេណអតិសន៍បរិយាកាស	ជំរុញសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចមូលដ្ឋាន
ធនធានបរិស្ថាន	១	សណ្ឋានដី	C	D	D	D	C			D	D		D	D	D	D
	២	ការហូរច្រោះដី	C	D	D	D	C			D	D		D	D	D	D
	៣	គុណភាពដី	C	D	D	C	C			D	D		D	D	D	D
	៤	គុណភាពទឹក	C	D	D	C	C			D	D		D	D	D	D
	៥	សម្លេង / ញ័រ	C	D	C	C	C			C	D		D	D	D	D
	៦	គុណភាពខ្យល់	C	D	C	D	C			C	D		D	D	D	D
	៧	ជលវិទ្យា	D	D	D	D	D			D	D		D	D	D	D
ធនធានជីវសាស្ត្រ	១	តំបន់ឆ្នេរ	D	D	D	D	D			D	D		D	D	D	D
	២	ព្រៃឈើ	B-	D	D	C	C			D	D		D	D	D	D
	៣	សត្វព្រៃ	C	D	D	C	C			D	D		D	D	D	D



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

	៨	ប្រព័ន្ធអេកូឡូស៊ីក្នុងទឹក (ផ្កាថ្ម)	D	D	D	D	D			D	D		D	D	D	D
ធនធានសេដ្ឋកិច្ច និងសង្គម	១	ការតាំងទីលំនៅ	B+	D	D	C	B-			D	D		D	B+	B+	B+
	២	មុខរបរ និងប្រាក់ចំណូល	B+	D	D	D	C			D	D		B+	B+	B+	A+
	៣	ការប្រើប្រាស់ដី	B+	D	D	D	C			D	D		D	D	B+	B+
	៤	ការប្រើប្រាស់ទឹក	B+	D	D	D	D			D	D		D	D	B+	B+
	៥	ការប្រើប្រាស់ថាមពល	A+	D	D	D	D			D	D		D	D	B+	A+
	៦	ហេដ្ឋារចនាសម្ព័ន្ធ	B+	D	D	D	D			D	D		D	D	B+	B+
	៧	ការអប់រំ	B+	D	D	D	D			D	D		D	D	B+	B+
	៨	សុខភាពសាធារណៈ	C	D	C	C	C			C	D		D	D	B+	B+
	៩	វប្បធម៌/ប្រពៃណី	D	D	D	D	D			D	D		D	D	D	D
	១០	តំបន់ទេសចរណ៍	D	D	D	D	D			D	D		D	D	D	D
	១១	ជនជាតិដើមភាគតិច	D	D	D	D	D			D	D		D	D	D	D
	១២	គមនាគមន៍	B+	D	C	D	C			D	D		D	D	B+	B+
	១៣	ទូរគមនាគមន៍	B-	D	D	D	D			D	B-		D	D	B+	B+
ផ្សេងៗ	១	គ្រោះថ្នាក់ដោយឆក់អគ្គិសនី ឬ គ្រោះថ្នាក់នានា	C	D	C	C	C			C	C		D	D	D	D

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ចំណាត់ថ្នាក់ (កម្រិត):

A-: ហេតុប៉ះពាល់អវិជ្ជមានខ្លាំង (តម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញពីព្រោះហេតុប៉ះពាល់អវិជ្ជមានមិនអាចកាត់បន្ថយបាន)

B-: ហេតុប៉ះពាល់អវិជ្ជមានមធ្យម (ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានអាចកាត់បន្ថយបាន)

C: ហេតុប៉ះពាល់អវិជ្ជមានតិចតួច ឬហេតុប៉ះពាល់អវិជ្ជមានមិនប្រាកដប្រជា

D: គ្មានហេតុប៉ះពាល់បរិស្ថាន ឬ មិនតម្រូវឱ្យធ្វើការសិក្សាបន្ថែម

A+: ហេតុប៉ះពាល់ជាវិជ្ជមានខ្លាំង

B+: ហេតុប៉ះពាល់វិជ្ជមានគួរឱ្យកត់សម្គាល់

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៦.៤ ការពិពណ៌នាហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន

ដោយផ្អែកទៅលើទំហំ និងសកម្មភាពរបស់គម្រោង ការប្រើតារាងបញ្ជីផ្ទៀងផ្ទាត់ (Checklist) របស់គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ដែលមានស្រាប់ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញរបស់ក្រុមហ៊ុន Alex Corporation អាចឱ្យយើងកំណត់បាននូវហេតុប៉ះពាល់បរិស្ថាន និងសង្គមមួយចំនួនដែលអាចកើតមានឡើងនៅក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង និងដំណាក់កាលប្រតិបត្តិគម្រោង ដូចបង្ហាញជូននៅក្នុងតារាងម៉ាទ្រីក ៦.១ ខាងលើ។

៦.៤.១ ដំណាក់កាលមុនប្រតិបត្តិគម្រោង

ក្នុងដំណាក់កាលនេះ ត្រូវបានចែកចេញជាពីរមួមាន ដំណាក់កាលរចនាគម្រោង និងដំណាក់កាលសាងសង់។

៦.៤.១.១ ដំណាក់កាលរចនាគម្រោង (Project Design)

ដំណាក់កាលរចនាគម្រោង ជាដំណាក់កាលដំបូងដែលគម្រោងត្រូវបានពិចារណាគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យដំណើរការសាងសង់ និងប្រតិបត្តិគម្រោងប្រព្រឹត្តទៅបានល្អ។ សកម្មភាពក្នុងដំណាក់កាលនេះរួមមានការរៀបចំការជ្រើសរើសផ្លូវរត់ខ្សែបញ្ជូន ទីតាំងបោះបង្គោលអគ្គិសនី។ រាល់សកម្មភាពទាំងនេះវាមានឥទ្ធិពលទៅលើបរិស្ថានធម្មជាតិ (ធនធានរូបសាស្ត្រ និងជីវសាស្ត្រ) និងបរិស្ថានសង្គម (ធនធានសេដ្ឋកិច្ច-សង្គម) មានដូចខាងក្រោម៖

ក. សតិអារម្មណ៍ប្រជាសហគមន៍

នៅដំណាក់កាលនេះក្រុមហ៊ុននឹងចុះធ្វើការសិក្សាជ្រើសរើសផ្លូវ សម្រាប់រៀបចំខ្សែបញ្ជូនដែលដំណឹង និងសកម្មភាពនៃការចុះសិក្សានេះ អាចធ្វើឱ្យមានការប៉ះពាល់ដល់សតិអារម្មរបស់ប្រជាសហគមន៍ស្តីពីហេតុប៉ះពាល់ដល់ផ្ទះសម្បែង ដីធ្លី និងផលដំណាំរបស់ពួកគេ។ លើសពីនេះអាចធ្វើឱ្យប្រជាសហគមន៍ទទួលការភិតភ័យទៅនឹងកម្រិតជីវភាពប្រចាំថ្ងៃ គឺកាន់តែក្រៗទៅដោយសារតែមានការផ្លាស់ប្តូរមុខរបរភ្លាមៗ ដែលធ្វើឱ្យពួកគាត់មិនអាចទម្លាប់នឹងកម្រិតជីវភាពនោះបាន។

វិធានការកាត់បន្ថយ

- ក្រុមហ៊ុនធ្វើការប្រឹក្សាយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធអំពីគោលការណ៍ទូទៅ សម្រាប់កំណត់គន្លងផ្លូវខ្សែបញ្ជូនអគ្គិសនី ដើម្បីកាត់បន្ថយហេតុប៉ះពាល់ដែលអាចនឹងកើតមានក្នុងកម្រិតអតិបរមា។

Draft

- ក្រុមហ៊ុនធ្វើការផ្សព្វផ្សាយដល់ប្រជាជន បើសិនជាទទួលរងការប៉ះពាល់ទៅលើដីធ្លី ដំណាំ និងលំនៅដ្ឋានពីសកម្មភាពគម្រោង នោះគម្រោងនឹងដោះស្រាយជូនតាមតម្លៃទីផ្សារនៃទ្រព្យសម្បត្តិដែលប៉ះពាល់តាមការជាក់ស្តែង។
- ការបម្លាស់ទីលំនៅរបស់ពួកគាត់ គឺអាចទិញដីនៅក្នុងតំបន់របស់ពួកគាត់ដដែលតែតម្រូវស្ថិតនៅឆ្ងាយពីតំបន់ នៃគន្លងខ្សែបញ្ជូនអគ្គិសនីជៀសវាងកើតមានគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ មួយវិញទៀតអាចធ្វើឱ្យពួកគាត់មិនសូវមានការព្រួយបារម្ភចំពោះសេវាកម្មក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ឡើយ។

៦.៤.២ ដំណាក់កាលសាងសង់គម្រោង (Project Construction Phase)

ក្នុងដំណាក់កាលនេះ សកម្មភាពមួយចំនួននៃការសាងសង់ដូចជាសកម្មភាព ឈូសឆាយដី ការពង្រាបដីស្រទាប់លើ សាងសង់មូលដ្ឋានស្នាក់នៅរបស់កម្មករ ការដឹកជញ្ជូនសម្ភារៈជាដើម អាចបង្កហេតុប៉ះពាល់ទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម មួយចំនួនដូចខាងក្រោម៖

៦.៤.២.១ ធនធានរូបសាស្ត្រ

ក. សណ្ឋានដី

នៅដំណាក់កាលនេះ ទ្រង់ទ្រាយសណ្ឋានដី និងហានលេខា ត្រូវប្រែប្រួលដោយសារការឈូសឆាយដីទួល ឬដំបូកខ្ពស់ និងការចាក់បំពេញដីត្រង់តំបន់ទាប ដើម្បីពង្រាបដីឱ្យរាបស្មើសម្រាប់ធ្វើការសាងសង់ផ្លូវចូលការដ្ឋាន និងទីតាំងសង់បង្គោល។

វិធានការកាត់បន្ថយ

- ក្រុមហ៊ុនធ្វើការឈូសឆាយដីទៅតាមលក្ខណៈសណ្ឋានដី សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់គម្រោងទៅតាមផែនការមេរបស់ក្រុមហ៊ុន ដោយមានការត្រួតពិនិត្យ និងវាយតម្លៃយ៉ាងត្រឹមត្រូវពីមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីកាត់បន្ថយនូវការប្រែប្រួលសណ្ឋានដីតំបន់គម្រោងឱ្យស្ថិតនៅកម្រិតអប្បបរមា។
- ក្រុមហ៊ុនរៀបចំយកអាចម៍ដីពីទីទួលដែលបានមកពីការឈូសឆាយ ទៅចាក់បំពេញនៅតំបន់ទំនាប ឬកន្លែងដែលមានគ្រលុកធំនៅតំបន់ក្នុងតំបន់គម្រោង ដោយក្រុមហ៊ុនមិនទុកអាចម៍ដីទាំងនោះចោលពាសវាលពាសកាលនោះឡើយ។
- ក្រុមហ៊ុននឹងបញ្ជាឱ្យអ្នកមៅការសាងសង់លុបរណ្តៅ និងពង្រាបហើយសម្អាតទីតាំងទាំងនោះឱ្យស្អាតដូចដើមវិញ ដើម្បីរក្សាឱ្យបាននូវទំរង់សណ្ឋានដីក្នុងទីតាំងគម្រោង។

Draft

ខ. គុណភាពទឹក និងការចោលសំណល់រឹង-រាវ

ការឈូសឆាយដីក្នុងតំបន់គម្រោង ដើម្បីសាងសង់បង្គោលភ្លើង និងផ្លូវចូលការដ្ឋាននឹងធ្វើឱ្យប៉ះពាល់ដល់ទឹកលើដី ដោយសារការបុក/ខួងគ្រឹះ ការធ្លាក់កំទេចស៊ីម៉ង់ត៍ ដី និងសំណល់ផ្សេងៗ ចូលទៅក្នុងទឹកលើដីនៅតំបន់ក្បែរខាង។

ចំណែក ការចោលសំណល់រឹងដែលមានប្រភពចេញពីសំណល់សម្ភារៈសាងសង់ សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗមកពីការប្រើប្រាស់របស់កម្មករគម្រោង និងការបង្ហូរសំណល់រាវពីកន្លែងស្នាក់នៅ ឬពីការហៀរកំពប់សារធាតុប្រេងពីគ្រឿងចក្រ និងរថយន្ត ក៏បង្កឱ្យមានការប៉ះពាល់ដល់គុណភាពទឹកផងដែរ ទោះបីជាការសាងសង់នៅតាមតំបន់បង្គោលនីមួយៗមានរយៈពេលខ្លីក៍ដោយ។

នៅក្នុងរយៈពេលនេះ អាចនឹងមានសំណល់រឹងជាច្រើនដែលបានមកពីសម្ភារៈសាងសង់ដូចជាកំណាត់ដែក កំទេចស៊ីម៉ង់ត៍ជាដើម ក៏ដូចគ្នានោះដែរ ចំពោះសំណល់ដែលបង្កើតឡើងដោយកម្មករ (Household/living waste)។

ចំពោះសំណល់រាវរួមមានសំណល់ចេញពីការសាងសង់ សំណល់ប្រេង សំណល់ចេញពីការប្រើប្រាស់ទឹក របស់បុគ្គលិកកម្មករសំណង់ និងសំណល់ចេញពីបង្គន់អនាម័យ។

ដោយឡែក ការឈូសឆាយដែលមិនមានផែនការច្បាស់លាស់ ក្នុងការកាត់បន្ថយការហូរច្រោះ និងសំណឹកដី ដោយបង្កឱ្យមានការកើនឡើងនូវកករល្បាប់ម៉ដួ/កក់ ដែលនាំមានការបំពុលដល់ទឹកអូរ ទឹកព្រែក ។ល។

វិធានការកាត់បន្ថយ

ទោះបីជាមានហេតុប៉ះពាល់អវិជ្ជមានយ៉ាងណាក៍ដោយ ក្រុមហ៊ុនមានវិធានការការពារ ឬកាត់បន្ថយហេតុប៉ះពាល់ជាយថាហេតុដែលបណ្តាលមកពីសកម្មភាព និងសម្ភារៈសាងសង់ដល់គុណភាពទឹក ដោយមានវិធានការទុកដាក់សំណល់ទាំងអស់ឱ្យបានត្រឹមត្រូវមួយចំនួនដូចខាងក្រោម៖

- ក្រុមហ៊ុនបានយកសំណាកទឹកនៅតាមប្រភពទឹកនីមួយៗ ទៅពិនិត្យនៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ដោយយកសំណាកទឹកពីប្រភពទាំងនោះទៅវិភាគលើប៉ារ៉ាម៉ែត្រចំនួន២២ ហើយលទ្ធផលនៃការវិភាគនេះមានលក្ខណៈងាយស្រួល សម្រាប់ធ្វើការប្រៀបធៀបពីគុណភាពទឹកនៅពេលមានសកម្មភាពសាងសង់។
- សាងសង់កន្លែងស្តុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវ ដោយមិនឱ្យកំពប់លើដី ដែលនាំឱ្យហូរចូលក្នុង ព្រែកទឹកសាប ឬអូរ ហើយក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីន/គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលថ្មីៗល្អ និងត្រូវបានត្រួតពិនិត្យជាប្រចាំយ៉ាងម៉ត់ចត់មុននឹងប្រតិបត្តិ ដើម្បីធានាមិនឱ្យមានការលេច/ជ្រាបប្រេង។

Draft

- ពិនិត្យនូវគ្រឿងចក្រមុននឹងចេញប្រតិបត្តិការ ដើម្បីជៀសវាងការជ្រាប ឬលេចប្រេងចេញពីម៉ាស៊ីន។
- ធ្វើការឈូសឆាយដីនៅដូវប្រាំង។ ក្នុងករណីមានការឈូសឆាយដីរដូវវស្សា ក្រុមហ៊ុននឹងប្រតិបត្តិក្នុងទ្រង់ទ្រាយតូច ហើយនៅក្នុងស្ថានភាពលើសណ្តានដីរាបស្មើ ហើយក្រុមហ៊ុនធ្វើរបាំងការពារកកវដី ឬកំទេចកំទីបើចាំបាច់ ដើម្បីកុំឱ្យហូរដីចូលទៅក្នុងប្រភពទឹក។
- ធ្វើការអប់រំដល់កម្មករឱ្យយល់ដឹងអំពីអនាម័យនៅក្នុងតំបន់សាងសង់ ដោយត្រូវចេញខ្ចប់រាល់សំណល់ផ្ទះបាយរបស់ខ្លួន និងទុកដាក់នៅកន្លែងកំណត់ឱ្យត្រឹមត្រូវ។
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់ការដ្ឋានសាងសង់ ដោយតម្រូវឱ្យកម្មករគោរពយ៉ាងម៉ឹងម៉ាត់ ឬត្រូវទទួលពិន័យយ៉ាងតឹងរឹង។
- ប្រើប្រាស់បច្ចេកវិទ្យាឈានមុខ និងម៉ាស៊ីនទំនើប (Advanced technology and machinery) ដើម្បីកាត់បន្ថយការលេចជ្រាបប្រេង ហើយត្រូវធ្វើការត្រួតពិនិត្យរាល់គ្រឿងចក្រនីមួយៗជាប្រចាំ។
- បិទស្លាកបម្រាម (Use Warning Label) សម្រាប់សម្គាល់ចំពោះសម្ភារៈដែលមានជាតិពុល និងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថានដូចជាប្រេងឥន្ធនៈ ឬថ្នាំលាបជាដើម។

គ. គុណភាពខ្យល់

ការប្រើប្រាស់គ្រឿងយន្ត ការបុក/ខួងគ្រឹះ ការប្រើប្រាស់ថ្នាំលាប ការប្រើប្រាស់ប្រេងឥន្ធនៈ និងការបោះចោលសំណល់រឹង-រាវធ្វើឱ្យមានធូលី សារធាតុគីមី និងក្លិនស្អុយ សាយភាយចេញទៅបរិយាកាសដែលធ្វើឱ្យគុណភាពខ្យល់ត្រូវរងការបំពុល។ លើសពីនេះទៀត សកម្មភាពរបស់ក្រុមហ៊ុនប្រើប្រាស់ម៉ាស៊ីនភ្លើងទាំងស្រុង ដោយសារតំបន់គម្រោងពុំទាន់តបណ្តាញអគ្គិសនីឡើយ ហើយការបញ្ចេះម៉ាស៊ីនភ្លើងអាចបង្កឱ្យមានការសាយភាយឧស្ម័នពុលទៅក្នុងបរិយាកាស។

វិធានការកាត់បន្ថយ

រាល់ការកាត់បន្ថយឥទ្ធិពលដែលធ្វើឱ្យមានការប៉ះពាល់ដល់គុណភាពខ្យល់ ក្រុមហ៊ុនបានគិតគូរនូវវិធានការមួយចំនួនដូចខាងក្រោម៖

- ក្រុមហ៊ុននឹងត្រូវតម្រូវឱ្យអនុវត្តជាប្រចាំចំពោះការត្រួតពិនិត្យមើលម៉ាស៊ីន គ្រឿងចក្រ និងឧបករណ៍នានា ដើម្បីធានាថារបស់របរទាំងនេះអាចធ្វើការបានល្អ។
- សេវាកម្មថែរក្សាការពារជាទៀងទាត់នៃគ្រឿងចក្រ និងឧបករណ៍សាងសង់ ត្រូវអនុវត្តន៍ឱ្យបានតឹងរឹង។
- សំណល់នៃសម្ភារៈសាងសង់នៅក្នុងការដ្ឋាន ត្រូវច្រកចូលទៅក្នុងការ៉ុង/បាវ រួចចងឱ្យជិតដាក់ចូលក្នុងបន្ទប់ដាក់សំណល់ មុននឹងធ្វើការដឹកជញ្ជូនយកទៅចោលទៅតាមការកំណត់

Draft



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

របស់ក្រសួងបរិស្ថាន។ ក្រុមហ៊ុនត្រូវប្រើប្រាស់រថយន្តដឹកសំណល់ដោយគ្រប់យ៉ាងត្រឹមត្រូវ ជៀសវាងការហុយ ឬធ្លាក់កំទេចថ្ម ឬដីនៅតាមដងផ្លូវ។

- បាញ់ស្រោចទឹកនៅក្នុងតំបន់សាងសង់ និងនៅផ្លូវទៅកាន់តំបន់សាងសង់បើចាំបាច់។
- ប្រើប្រាស់គ្រឿងចក្រថ្មីៗ ដែលមិនមានការបញ្ចេញផ្សែងពុលទៅលើខ្យល់/បរិយាកាស។
- នៅពេលមានការរិះគន់ពីធូលី និងឧស្ម័នពីសំណាក់ប្រជាជនដែលរស់នៅតាមដងផ្លូវ ចូលតំបន់គម្រោង នោះក្រុមហ៊ុនត្រូវធ្វើការត្រួតពិនិត្យ និងយកចិត្តទុកដាក់ពីសកម្មភាពដែលមានការបំពុលខ្យល់ ព្រមទាំងកាត់បន្ថយនូវការបំពុលនេះឱ្យដល់កម្រិតអប្បបរមាដែលប្រជាជនទទួលយកបាន។

ឃ. ការរំខានដោយសម្លេង និងរំញ័រ

ការសាងសង់គម្រោងនេះនៅឆ្ងាយពីទីប្រជុំជន និងទីកន្លែងរស់នៅរបស់ប្រជាជនហេតុនេះ ការរំខានដោយសម្លេង និងរំញ័រមិនបណ្តាលឱ្យប៉ះពាល់ដល់ប្រជាជនដែលរស់នៅតំបន់នោះទេ។ តែទន្ទឹមនឹងនោះក៏អាចប៉ះពាល់តិចតួចដល់កម្មករដែលធ្វើការនៅក្នុងតំបន់គម្រោងផងដែរ ជាពិសេសចំពោះអ្នកបញ្ជាគ្រឿងចក្រជ្រាលដើម្បីចៀសវាងហេតុប៉ះពាល់ដល់សោតវិញ្ញាណ (Noise-induced hearing loss) ក៏ប៉ុន្តែសម្លេងទាំងអស់នោះមិនអាចជះឥទ្ធិពលខ្លាំងដល់កម្មករដែលធ្វើការនៅតំបន់នោះទេ។

ដូចនេះការរំខានដោយសម្លេង និងរំញ័រមិនបានបង្កជាបញ្ហាដល់កម្មករ ឬប្រជាជននោះទេ។

វិធានការកាត់បន្ថយ

- គ្រឿងទប់សម្លេងដូចជា ឧបករណ៍កាត់បន្ថយសម្លេង (sound absorbtion) ត្រូវបំពាក់នៅពេលដែលយល់ថាមានការចាំបាច់ ដើម្បីកាត់បន្ថយការបញ្ចេញសម្លេងពីគ្រឿងចក្រ និងឧបករណ៍ស្ទាងសង់គ្រប់ប្រភេទ ដែលត្រូវបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។
- រាល់សកម្មភាពសាងសង់ដែលបង្កើតឱ្យមានកម្រិតសម្លេងខ្លាំង លើសពី៨៥ដេស៊ីបែល ក្រុមហ៊ុនត្រូវកំណត់ពេលវេលាឱ្យមានតែនៅពេលថ្ងៃប៉ុណ្ណោះ (០៦:០០ព្រឹក ដល់០៦:០០ល្ងាច) ដើម្បីជៀសវាងការរំខានដោយសម្លេងទៅដល់ការរស់នៅរបស់ប្រជាជនដែលនៅក្បែរនោះ និងការសម្រាករបស់កម្មករ។
- ចំពោះកម្មករដែលប្រឈមទៅនឹងសម្លេងខ្លាំង និងមានរយៈពេលយូរ ត្រូវពាក់ឆ្នុកចុកត្រចៀក (Ears Plug) និង(Ears Muff) ដែលផ្តល់ឱ្យដោយក្រុមហ៊ុន (Personal hearing

Draft

devices) (ប្រកាសលេខ១៣៨ ស.ក.ប.ឃ ចុះថ្ងៃទី២២/០៩/២០០៣ ស្តីពីសម្លេងក្នុងទីកន្លែងធ្វើការ នាយកដ្ឋានពេទ្យការងារ)។

- ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងចក្រ ព្រមទាំងម៉ាស៊ីនភ្លើងធុនទំនើបដែលបញ្ចោញសម្លេងតិចមិនឱ្យប៉ះពាល់ដល់សុខភាពរបស់កម្មករ។
- កម្រិតសម្លេងចេញពីប្រភពគ្រឿងចក្រ នៅក្នុងចម្ងាយ១០០ម៉ែត្រ ទៅកាន់បរិស្ថានដែលនៅជុំវិញគឺមិនលើសពី៧៥dB(A)នៅពេលថ្ងៃ។ ក្រុមហ៊ុនត្រូវតម្រូវឱ្យប្រើប្រាស់ឧបករណ៍ម៉ាស៊ីនដែលមានកម្រិតសម្លេង និងរំញ័រទាបនៅគ្រប់ពេលទាំងអស់ គឺជាការចាំបាច់ (តំបន់ប្រជាជនរស់នៅ<60dB តំបន់ចម្រុះ<៦០dB តំបន់ពាណិជ្ជកម្ម<៧០dB និងតំបន់ងាយទទួលរងការប៉ះពាល់ដោយសម្លេង <៥៥dB)។

ង. ប្រព័ន្ធផ្លូវទឹក

ក្នុងដំណាក់កាលប្រតិបត្តិគម្រោង អាចនឹងមានការកកស្ទះផ្លូវទឹកតាមកូនអូរតូចៗ ដែលអ្នកម៉ៅការសាងសង់ផ្លូវចូលក្នុងគោលបំណងសាងសង់បង្គោល ហើយនៅពេលចប់ការសាងសង់ក្រុមអ្នកម៉ៅការទាំងនោះមិនបានកាយ សម្អាតដីនោះឱ្យបានដូចដើមវិញដែលជាកត្តានាំឱ្យមានការកកស្ទះមុខទឹក នឹងធ្វើឱ្យជន់លិចតំបន់ខាងលើ ឬតំបន់ខាងក្រោមដែលមានសភាពខ្វះខាតទឹកប្រើប្រាស់។

វិធានការកាត់បន្ថយ

ម្ចាស់គម្រោងត្រូវតម្រូវឱ្យអ្នកម៉ៅការ សម្អាតទីតាំង រួមមានការកាយសម្អាតផ្លូវទឹកដែលខ្លួនបានបិទធ្វើផ្លូវចូលសាងសង់បង្គោលភ្លើងរបស់គម្រោងនេះ។

ច. ការហូរច្រោះ និងគុណភាពដី

អាចមានការហូរច្រោះជញ្ជាំងរណ្តៅដី ឬគំនរអាចម៍ដី ដែលធ្វើឱ្យល្អក់ទឹកខ្លាំងនៃប្រភពទឹកនៅក្បែរនោះ បើសិនជាម្ចាស់គម្រោងមិនបានគិតគូរអំពីបញ្ហានេះទេ។

ជាងនេះទៅទៀត ការចាក់ដីបំពេញលើកកម្ពស់នៅតំបន់តាមជើងបង្គោល ឬអនុស្ថានីយ៍ដែលជាពិស្រែសតំបន់វាលស្រែជុំវិញ ហើយនៅរដូវភ្លៀងមានការហូរច្រោះដីនេះទៅគ្របលើដីស្រែដែលជាកត្តាបណ្តាលឱ្យបាត់បង់គុណភាពដីនៅកន្លែងនោះផងដែរ។

វិធានការកាត់បន្ថយ

ពេលសាងសង់ម្ចាស់គម្រោងត្រូវត្រួតពិនិត្យអ្នកម៉ៅការសាងសង់ជាប្រចាំ នូវជញ្ជាំងរណ្តៅដី ឬគំនរអាចម៍ដីដោយយោងតាមឯកសារនៃកិច្ចសន្យាការងារ ហើយត្រូវកាយលុបរណ្តៅគ្រឹះ និងពង្រាបដីឱ្យដូចដើមវិញ។

Draft

ជាមួយគ្នានេះផងដែរ ការសាងសង់គម្រោងនេះភាគច្រើន គឺត្រូវបានអនុវត្តន៍នៅរដូវប្រាំង ដែលមានការប៉ះពាល់ដល់ផ្នែកនេះតិចតួចបំផុត។

ឆ. ការបំពុលដី

ដូចគ្នានឹងការបំពុលទឹក និងការបំពុលខ្យល់ដែរ ក្នុងដំណាក់កាលនៃការសាងសង់គម្រោងនេះ មានការបំពុលដីខ្លះៗ ដោយសារសកម្មភាពការងារស្ងាងសង់ ដូចជាការជីករណ្តៅបង្គោល ការគរអាចម៍ដីមិនបានល្អ ការគ្រប់គ្រងការងារក្នុងការចាក់គ្រឹះមិនបានល្អ (ការកំពប់ស៊ីម៉ង់ត៍ ទឹកស៊ីម៉ង់ត៍ ជាដើម) លើដី ដែលទាំងនេះជាកត្តាបណ្តាលឱ្យមានការបំពុលដីក្នុងតំបន់គម្រោង។

ដូចគ្នានេះផងដែរ ក្នុងករណីពុំមានការគ្រប់គ្រងសំណល់រឹង ឬសំណង់រាវមិនបានល្អនៅការដ្ឋាន កន្លែងស្មាក់នៅបុគ្គលិក រោងជាង ឃ្លាំង នាំឱ្យមានការបំពុលដីក្នុងតំបន់គម្រោងផងដែរ។

វិធានការកាត់បន្ថយ

ពេលសាងសង់គម្រោង ម្ចាស់គម្រោងត្រូវត្រួតពិនិត្យអ្នកមៅការសាងសង់ជាប្រចាំ ត្រូវពិនិត្យរណ្តៅ និងគំនរអាចម៍ដីយោងតាមឯកសារនៃកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវ ដោយធ្វើយ៉ាងណាឱ្យមានការកប់ ឬគំនរអាចម៍ដីឱ្យបានត្រឹមត្រូវតាមសភាពដើម។

ជាងនេះទៅទៀត ត្រូវត្រួតពិនិត្យមើលកន្លែងលាយ និងចាក់បេតុង កន្លែងលាងថ្ម ដោយជៀសវាងមិនមានការបំពុលដីក្នុងតំបន់គម្រោងនោះឡើយ។

ក្នុងករណីមានការលេចធ្លាយប្រេងលើសពី ១.០០០លីត្រ ម្ចាស់គម្រោងត្រូវមានវិធានការជាបន្ទាន់ ដោយមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថានប័នជំនាញពាក់ព័ន្ធ ដើម្បីយកប្រេងដែលកំពប់ និងកើបយកដីដែលប្រេងហូរលើនោះចេញ ហើយទុកដាក់វាឱ្យមានសុវត្ថិភាព និងរក្សាគម្លាតឱ្យឆ្ងាយពីប្រភពទឹក ដោយធានាឱ្យបានថាសំណល់ប្រេងទាំងនោះនឹងមិនមានការប៉ះពាល់ដល់គុណភាពទឹក និងដីក្នុង ឬក្បែរតំបន់គម្រោង។

ក្នុងនោះផងដែរ ម្ចាស់គម្រោងត្រូវអប់រំដល់បុគ្គលិក ឬកម្មករក្នុងការបោះបង់សំណល់រឹង ឬរាវ ជាពិសេសការកំពប់ប្រេងឥន្ធៈ ដែលអាចធ្វើឱ្យខូចគុណភាពទឹក និងគុណភាពដីក្នុងគម្រោង។ ក្នុងនោះផងដែរ ម្ចាស់គម្រោងត្រូវប្រមូលយកសំណល់ដូចជា (សំណល់ប្រេងបាតចាស់ៗ កំប៉ុង) ឱ្យបានត្រឹមត្រូវ ហើយធ្វើការញែកសំណល់ដែលអាចកែច្នៃ និងប្រើប្រាស់ឡើងវិញដោយឡែក។

ជ. ការគ្រប់គ្រងសំណល់អាចម៍ដី

នៅក្នុងដំណាក់កាលសាងសង់រយៈពេល៣ឆ្នាំនេះ សណ្ឋានដីអាចមានលក្ខណៈប្រែប្រួលតិចតួចនៅក្នុងតំបន់ដែលសាងសង់បង្គោលភ្លើងត្រង់តំបន់ដែលចាក់ដីលើកកម្ពស់ និងព្រមទាំងមានការឈូឆាយដីទៅតាមលក្ខណៈសណ្ឋានដីដែលជាហេតុបង្កឱ្យមានផលប៉ះពាល់ និងមានគំនរអាចម៍ដីនេះកើតឡើង។

Draft

វិធានការកាត់បន្ថយ

ក្រុមហ៊ុនរៀបចំយកអាចម៍ដីពីទីទួលដែលបានមកពីការឈូសឆាយ ទៅចាក់បំពេញនៅតំបន់ទំនាប ឬកន្លែងដែលមានគ្រលុកធំនៅក្នុងតំបន់គម្រោង។ ជាពិសេសក្រុមហ៊ុនលុបបណ្តៅ និងពង្រាបដីហើយសម្អាតទីតាំងទាំងនោះឱ្យស្អាតដូចដើមវិញដើម្បីរក្សាឱ្យបាននូវទម្រង់សណ្ឋានដី។

៦.៤.២.២ ធនធានជីវសាស្ត្រ

ក. ធនធានព្រៃឈើ និងទីជម្រករបស់សត្វ

តាមការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ក្នុងការវិភាគទីតាំងសាងសង់បង្គោល និងគម្របព្រៃឆ្នាំ២០១០បានបង្ហាញថាក្នុងចំណោមបង្គោលភ្លើងដែលត្រូវសាងសង់សរុបចំនួន៤២៦បង្គោល ក្នុងនោះមានបង្គោលខ្សែភ្លើងចំនួន៣៦៦បង្គោល ត្រូវបានសាងសង់លើតំបន់ដីពុំមានគម្របព្រៃ ១៦បង្គោលត្រូវបានសាងសង់លើតំបន់ព្រៃល្បាះ ១៦បង្គោលត្រូវបានសាងសង់លើតំបន់ព្រៃស្រោង ១៣បង្គោលត្រូវបានសាងសង់លើតំបន់ប្រភេទព្រៃផ្សេងៗ ៨បង្គោលត្រូវបានសាងសង់លើតំបន់ព្រៃគម្ពោតបៃតង និង៧បង្គោលត្រូវបានសាងសង់លើតំបន់ព្រៃពាក់កណ្តាលស្រោង។

ចំពោះកម្មករដែលបម្រើការងារក្នុងតំបន់គម្រោង ក៏នឹងអាចមានការធ្វេសប្រហែសនានាដូចជាការចោលកន្ទុយបារី ការបង្កាត់ភ្លើងសម្រាប់ចម្អិនអាហារជាដើម ដែលកត្តានេះបានបណ្តាលឱ្យមានភ្លើងឆេះព្រៃ។

វិធានការកាត់បន្ថយ

- ការកាប់ព្រៃឈើត្រូវធ្វើឡើងក្នុងដែនកំណត់ សម្រាប់តែតម្រូវការទីកន្លែងការសាងសង់ និងនៅសងខាងបណ្តាញខ្សែកាបចម្ងាយ៣០មែត្រប៉ុណ្ណោះ ។
- ក្រុមហ៊ុនថែរក្សាប្រភេទឈើ ឬបណ្តុំព្រៃដែលមានលក្ខណៈបច្ចេកទេសសម្រាប់ជីវៈចម្រុះការពារបរិស្ថាន ព្រៃឈើនៅលើភ្នំ និងទីជម្រាលមាត់ ស្ទឹងព្រែក និងតំបន់អភិរក្ស។
- មុននឹងធ្វើការឈូសឆាយដី ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់គម្រោង ក្រុមហ៊ុននឹងអនុវត្តទៅតាមផែនការម៉ែក្រុមហ៊ុន និងសុំការអនុញ្ញាតពីក្រសួងបរិស្ថានទៅតាមនីតិវិធីច្បាប់ជាធរមាន។
- ដើមរឈើទាំងអស់នៅក្នុងទីតាំងគម្រោង ដែលត្រូវបានកាប់សម្រាប់គោលបំណងនៃសិទ្ធិប្រើប្រាស់ទីតាំងដែលត្រូវសាងសង់តែប៉ុណ្ណោះ ប្រសិនបើដើមឈើទាំងនោះមានតម្លៃសេដ្ឋកិច្ចនោះ ក្រុមហ៊ុនត្រូវបង់ចំណូលជូនរដ្ឋស្របតាមច្បាប់ និង

Draft



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

បទបញ្ញត្តជាធរមាន ទើបមានសិទ្ធិប្រើប្រាស់ ឬលក់ឈើទាំងនោះដោយស្របច្បាប់។ បើពុំនោះទេ ឈើដែលបានកាប់រួចហើយត្រូវប្រគល់ជូនរដ្ឋវិញ។

- ក្រុមហ៊ុននឹងធ្វើការពិន័យ ឬបញ្ឈប់ពីការងារដល់កម្មករណាដែលកាប់ដើមឈើដោយពុំមានការអនុញ្ញាតជាមុនពីអ្នកគ្រប់គ្រងគម្រោង។
- ធ្វើការអប់រំណែនាំដល់កម្មករទាំងអស់របស់ក្រុមហ៊ុន ឱ្យមានការប្រុងប្រយ័ត្នចំពោះការបង្កាត់ភ្លើងសម្រាប់គោលបំណងផ្សេងៗ និងការចោលកន្ទុយបារី ដើម្បីជៀសវាងភ្លើងឆេះព្រៃ ហើយត្រូវរាយការណ៍ដល់អាជ្ញាធរមូលដ្ឋាននៅពេលខ្លួនប្រទះឃើញភ្លើងឆេះព្រៃក្នុងតំបន់គម្រោង ដើម្បីធ្វើការទប់ស្កាត់ឱ្យបានទាន់ពេលវេលា។
- ក្រុមហ៊ុនបំពាក់ឧបករណ៍បង្ការគ្រោះអគ្គីភ័យតំបន់ក្នុងតំបន់ការដ្ឋាន ដែលការរៀបចំណែះបានទទួលការណែនាំពីទីភ្នាក់ងារពន្លត់អគ្គីភ័យ និងត្រួតពិនិត្យជាប្រចាំ (រៀងរាល់១ខែ) ដើម្បីឱ្យដឹងពីប្រសិទ្ធិភាពនៃការប្រើប្រាស់ ។
- ក្រុមហ៊ុននឹងដាក់ស្លាកសញ្ញាសម្គាល់សម្រាប់សត្វឆ្លងកាត់ក្នុងតំបន់ព្រៃដែលមានការសាងសង់បង្គោលអគ្គិសនី។

ខ. ព្រៃការពារ/តំបន់ការពារ

ការសាងសង់ខ្សែបញ្ជូនអគ្គិសនី២៣០គីឡូវ៉ុល ពីស្វឹងហាវទៅកាន់អនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញមានការប៉ះពាល់បន្តិចបន្តួច លើព្រៃការពារក្បាលឆាយប្រវែងសរុប១.៨៥០ ម៉ែត្រ ដែលនាំឱ្យមានការប៉ះពាល់ដល់អេកូឡូស៊ីខ្លះៗ ជាពិសេសពពួកត្រី និងបក្សីដោយសារសកម្មភាពក្នុងការសាងសង់គម្រោង។

វិធានការកាត់បន្ថយ

ការសាងសង់គម្រោងនៅតំបន់នេះត្រូវធ្វើការដោយប្រុងប្រយ័ត្ន ដូចជាការងារដី ការងារបេតុង ការងារគ្រឹះ ត្រូវគោរពតាមបទដ្ឋានបច្ចេកទេស ត្រូវធ្វើឡើងតែនៅរដូវប្រាំងតែប៉ុណ្ណោះ។

ជាងនេះទៅទៀត ពេលសាងសង់ចប់ត្រូវលុបរណ្តៅគ្រឹះភ្លាម ដោយធ្វើការបង្ហាប់ដីឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារដីដូចបានចែងក្នុងលក្ខខណ្ឌការងារគម្រោង។

ត្រូវមានការរៀបចំគ្រប់គ្រងសំណល់រឹង-រាវឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព ជាពិសេសមិនឱ្យមានការបំពុលបរិស្ថានក្នុងតំបន់ព្រៃការពារនេះ។

Draft

ក. ពពួកសត្វព្រៃ

ពពួកសត្វព្រៃដែលមាននៅក្នុងតំបន់គម្រោង សាងសង់(បង្គោលអគ្គិសនី) ក្នុងតំបន់អភិរក្ស គីរីរម្យ ដែលអាចជាជម្រកសត្វដ៏ល្អសម្រាប់ពពួកបក្សី ល្មូន និងសត្វព្រៃនានា ដូចនេះប្រភេទសត្វ មួយចំនួននឹងមានការថយចុះដោយការបម្លាស់ទីទៅរស់នៅកន្លែងផ្សេង ដើម្បីស្វែងរកចំណីអាហារ ចិញ្ចឹមជីវិត។ តាមការសិក្សារបស់ក្រុមហ៊ុន បានបង្ហាញថា តំបន់គម្រោងមានប្រភេទសត្វដូចជា ថនិកសត្វ១០ប្រភេទ ឧរង្គសត្វ ឬល្មូនចំនួន ០៦ប្រភេទ បក្សីចំនួន០៨ប្រភេទ និងថលជលិកសត្វ ឬពពួកកង្កែប០៤ប្រភេទ។

មិនតែប៉ុណ្ណោះ សម្លេងចេញពីសកម្មភាពប្រើប្រាស់គ្រឿងចក្រ សម្រាប់ឈូសឆាយដី និង ការបញ្ចេះម៉ាស៊ីនភ្លើងក្នុងតំបន់គម្រោងនៅពេលយប់ក៏បាន ធ្វើឱ្យមានការរំខានដល់សត្វព្រៃដែល មានវត្តមាននៅក្នុងតំបន់នោះ ជាពិសេសការបន្តពូជរបស់សត្វ។ ដោយឡែកវាអាចនឹងមានការបរ បាញ់សត្វព្រៃពីសំណាក់បុគ្គលិក-កម្មកររបស់ក្រុមហ៊ុន។

វិធានការកាត់បន្ថយ

- ទីតាំងនៃការសាងសង់បង្គោលត្រូវសាងសង់ទៅតាមប្លង់មេរបស់ក្រុមហ៊ុន ដោយ បង្គោលភាគច្រើនត្រូវបានសាងសង់ជិតនឹងតាមបណ្តោយផ្លូវជាតិលេខ៤។
- កំណត់ពេលវេលាធ្វើការច្បាស់លាស់ដូចជាធ្វើការតែនៅពេលថ្ងៃ និងប្រើប្រាស់ម៉ាស៊ីន ភ្លើងបញ្ចេញសម្លេងស្របតាមស្តង់ដារ។
- ធ្វើការអប់រំដល់កម្មករ របស់ក្រុមហ៊ុនមិនឱ្យធ្វើការបរបាញ់សត្វគ្រប់ប្រភេទនៅតំបន់ គម្រោង និងធ្វើការគ្រប់គ្រងយ៉ាងណាកុំឱ្យមានបទល្មើសសត្វព្រៃនានា ដែលកើតឡើង នៅក្នុងតំបន់នេះ ដោយសហការជាមួយនឹងឧទ្យានុរក្សនៃឧទ្យានជាតិជាប្រចាំ។
- ក្រុមហ៊ុននឹងដាក់ស្លាកសញ្ញាសម្គាល់សម្រាប់សត្វឆ្លងកាត់ក្នុងតំបន់ព្រៃ ដែលមានការ សាងសង់បង្គោលអគ្គិសនី។

៦.៤.២.៣ ធនធានសេដ្ឋកិច្ច-សង្គម

ក. ទ្រព្យសម្បត្តិប្រជាសហគមន៍

គម្រោងនឹងតម្រូវឱ្យមានការកាប់ដើមឈើហូបផ្លែមួយចំនួន ស្របតាមបច្ចេកទេសចម្ងាយ ចន្លោះស្រាប់បណ្តាញបញ្ជូនអគ្គិសនី។ ដូចនេះគម្រោងនេះនឹងប៉ះពាល់ដើមឈើដែលស្របតាម បណ្តោយបង្គោលអគ្គិសនី និងប៉ះពាល់មរិវេណទទឹង៣០ម៉ែត្រ (ក្រោមគន្លងខ្សែបញ្ជូនអគ្គិសនី)។

ទីតាំងសាងសង់បង្គោល នឹងអាចប៉ះពាល់ដល់ដីលំនៅដ្ឋាន ដីស្រែ ចម្ការ ដើមឈើហូបផ្លែ របស់ប្រជាជន។

Draft

វិធានការកាត់បន្ថយ

- ការកាប់ដើមឈើនឹងត្រូវធ្វើឡើងក្នុងតំបន់ទីតាំងគម្រោង ដែលត្រូវការសាងសង់បង្គោល និងក្រោមគន្លងតែប៉ុណ្ណោះ។
- ការផ្លាស់គ្រឹះបង្គោល និងការតម្រង់បណ្តាញ/ ផ្លូវបញ្ជូនអគ្គិសនីដើម្បីបញ្ចៀសការកាប់ព្រៃឈើ និងឈើហូបផ្លែដែលតម្រូវឱ្យធ្វើឡើងក្នុងកន្លែងខ្លះ។
- ដាំដើមឈើឡើងវិញ ក្នុងចំនួនដើមឈើដែលបានបាត់បង់ក្នុងពេលជាក់លាក់ណាមួយ បន្ទាប់ពីចប់សកម្មភាពគម្រោងក្នុងទីតាំងនីមួយៗ ឬផ្តល់មូលនិធិបរិស្ថានសម្រាប់ការដាំដើមឈើឡើងវិញ។
- ប្រភេទហូបផ្លែដែលមានកម្ពស់ទាបជាង ៣ម៉ែត្រដែលមានទីតាំងក្រោមបរិវេណដែលប៉ះពាល់នឹងទុកឱ្យដុះតាមធម្មតា។ ប៉ុន្តែប្រភេទដើមឈើដែលមានកម្ពស់ខ្ពស់ជាង ៣ ម៉ែត្រចាំបាច់ត្រូវកាត់ចោល។ ឈើហូបផ្លែដែលខូចខាតនូវសហគមន៍ ដោយសកម្មភាពគម្រោងក្រុមហ៊ុននឹងសងការខូចខាតដោយផ្អែកលើលក្ខខណ្ឌ ខូចខាតជាក់ស្តែង និងអនុវត្តន៍គោលនយោបាយសំណងរបស់អគ្គិសនីកម្ពុជា។
- ក្រុមហ៊ុនប្រតិបត្តិនឹងចរចាជាមួយម្ចាស់ចម្ការ ដើម្បីដោះស្រាយការខូចខាតដំណាំកសិផល និងដើមឈើហូបផ្លែ ក្នុងគោលបំណងសុំការអនុញ្ញាតសាងសង់បណ្តាញបញ្ជូនឆ្លងកាត់ចម្ការឬនៅក្នុងដីកសិកម្មរបស់ពួកគាត់។
- តម្រូវឱ្យមានសំណងចំពោះការខូចខាតដើមឈើហូបផ្លែ និងដំណាំកសិផលរបស់សហគមន៍ ដោយសារសកម្មភាព សាងសង់គម្រោង។ ក្រុមហ៊ុនប្រតិបត្តិគម្រោងទទួលខុសត្រូវរាល់សំណងទាំងឡាយ ដែលស្របតាមអត្រា/គោលនយោបាយរបស់ IRC/MEF និងផ្អែកលើតម្លៃជំនួសក្នុងតំបន់នីមួយៗ ។

ខ. សុខភាព និងសុខុមាលភាពសាធារណៈ:

នៅដំណាក់កាលនេះអាចមានការប៉ះពាល់ដល់សុខភាពរបស់កម្មករសំណង់ ដូចជាការប្រើប្រាស់ទឹកមិនស្អាត ការទុកដាក់សំណល់មិនបានត្រឹមត្រូវ និងគ្រោះថ្នាក់ ឬរបួសបណ្តាលមកពីសកម្មភាពសាងសង់ ឬការប្រឈមមុខទៅនឹងជម្ងឺផ្សេងៗ។ គ្រោះថ្នាក់ជាយថាហេតុនៃការធ្លាក់ពីទីខ្ពស់ ចំពោះកម្មករ ដែលឡើងផ្សារតំណ ឬឡើងលើបង្គោលភ្លើងសម្រាប់តម្បៀបណ្តាញ ឬអាចធ្លាក់ពីឧបករណ៍សម្រាប់លើកឡើងក្នុងការសាងសង់បង្គោល និងបណ្តាញខ្សែអគ្គិសនី ឬអាចប៉ះពាល់ពីការធ្លាក់វត្ថុត្រូវ ជាពិសេស សាធារណៈជនដែលរស់នៅក្បែរទីតាំងគម្រោង (ប្រកាស០៧៧/ ១១ប.ក/ថប្រ.កចុះថ្ងៃទី ៣០/០៣/២០១១ ស្តីពីការផ្តល់ព័ត៌មាននៅការដ្ឋានសំណង់)។

Draft

ការរស់នៅរបស់សហគមន៍នឹងទទួលផលប៉ះពាល់ ដោយសារការរំខានដោយសារការរំខានដោយផ្សែង សម្លេង រំញ័រ សំណល់រឹង សំណល់រាវដែលជាប្រភពកកើតនៃជម្ងឺឆ្លងផ្សេងៗ រួមមានការរលាកផ្លូវដង្ហើម ជម្ងឺភ្នែក ជម្ងឺសើស្បែកជាដើម ប៉ុន្តែការបំពុលខ្យល់ដោយសារសកម្មភាពនេះមានរយៈពេលខ្លី។

ម្យ៉ាងទៀត ក្រុមហ៊ុននឹងជ្រើសរើសបុគ្គលិកពីក្រៅសហគមន៍មកធ្វើការលើគម្រោងនេះ ដែលនេះនឹងអាចប៉ះពាល់ដល់សុខភាព ប្រជាជននៅក្នុងសហគមន៍ដោយ ការចម្លង ជម្ងឺសង្គម ដូចជា ជម្ងឺអេដស៍ រោគស្វាយ និងការប្រើប្រាស់គ្រឿងញៀន ប្រសិនបើបុគ្គលិក គម្រោង មានទំនាក់ទំនងស្នេហា ឬការរួមភេទជាមួយសហគមន៍។

វិធានការកាត់បន្ថយ

- ផ្គត់ផ្គង់ទឹកន្លែងស្នាក់នៅសមរម្យ និងទឹកស្អាតដល់កម្មករ៖ ទឹកន្លែងស្នាក់នៅសម្រាប់កម្មករត្រូវបានរៀបចំឡើងដោយធ្វើយ៉ាងណាឱ្យមានពន្លឺ មានខ្យល់ចេញចូលបានគ្រប់គ្រាន់ និងមានភាពទូលាយសមរម្យ ដើម្បីចៀសវាងការរស់នៅកកកុញនៅក្នុងកន្លែងតែមួយ (បន្ទប់គួចចង្អៀតហួស) ដែលអំណោយផលដល់ការចម្លងជម្ងឺផ្សេងៗដូចជាជម្ងឺផ្លូវដង្ហើម។ល។
- តម្រូវការទឹកស្អាតសម្រាប់ប្រើប្រាស់នៅពេលកំពុងសាងសង់ គឺចាំបាច់ណាស់រួមទាំងទឹកសម្រាប់បរិភោគ និងការលាងសម្អាតរាងកាយប្រចាំថ្ងៃ។
- សាងសង់បង្គន់បណ្តោះអាសន្នដោយគោរពទៅតាមស្តង់ដារអនាម័យត្រឹមត្រូវ ដូចជាប្រភេទបង្គន់មានអាងស្តុកលាមកសឹបទឹកដល់កម្មរជាដើម។
- ធ្វើការអប់រំកម្មករនិង ប្រជាជនក្នុងមូលដ្ឋាន ដែលរស់នៅក្បែរការដ្ឋានគម្រោងឱ្យយល់ដឹងអំពីជម្ងឺកាមរោគ-អេដស៍ និងវិធីការពារជាពិសេសចំពោះបុគ្គលិក-កម្មករដែលឃ្លាតឆ្ងាយពីក្រុមគ្រួសារ ព្រោះពួកគេអាចស្វែងរកសេវាផ្លូវភេទនៅទីកន្លែងកំសាន្តនានាដែលអាចឱ្យគេប្រឈមទៅនឹងការឆ្លងជម្ងឺកាមរោគទាំងនោះ។
- ដើម្បីធ្វើការពិនិត្យពិគ្រោះព្យាបាលដល់បុគ្គលិក-កម្មករ និងសង្គ្រោះបន្ទាន់ក្នុងករណីដែលមានជម្ងឺ ឬរបួសធ្ងន់ធ្ងរដោយថាហេតុ។ បន្ថែមពីនេះទៀតគ្រូពេទ្យប្រចាំការត្រូវរាយការណ៍ជាបន្ទាន់ក្នុងករណីសង្ស័យ ឬរកឃើញករណីជម្ងឺឆ្លងរាតត្បាតណាមួយទៅដល់រដ្ឋអំណាចសុខាភិបាលដែលនៅជិតតំបន់សាងសង់របស់គម្រោង ។
- ប្រកាន់យកសុវត្ថិភាពជាចម្បងនៅការដ្ឋានសាងសង់ (Safety First)។

- គម្រោងនឹងបណ្តោះបណ្តាលកម្មករពីសុវត្ថិភាពនៃការធ្លាក់ពីទីខ្ពស់ និងផ្តល់នូវខ្សែក្រវ៉ាត់ការពារសម្រាប់កម្មករដែលឡើងទៅធ្វើការនៅទីខ្ពស់ ជាពិសេសលើឧបករណ៍ស្ងួច ឬបង្គោលអគ្គិសនី។
- ហាមមិនឱ្យអ្នកគ្មានភារកិច្ចចូលក្នុងការដ្ឋានសាងសង់ ដោយការដាក់ស្លាកសញ្ញាហាមឃាត់ជាដើម។
- គម្រោងនឹងមានការប្រើប្រាស់ម៉ាស៊ីនថ្មីៗ និងមានបំពាក់ឧបករណ៍កាត់បន្ថយសម្លេង និងផ្សែង ឱ្យស្របតាមបទដ្ឋាននៃការបញ្ចេញសម្លេង និងគុណភាពខ្យល់របស់ក្រសួងបរិស្ថាន ដើម្បីកុំឱ្យមានផលប៉ះពាល់ដល់ប្រជាជននៅក្នុងមូលដ្ឋាន។ ចំពោះម៉ាស៊ីនភ្លើង គម្រោងនឹងមានការប្រើប្រាស់ម៉ាស៊ីនទំនើប ដែលមានតម្រងចម្រោះផ្សែង និងមានបញ្ចេញសម្លេងតិចតួចបំផុត។

គ. គមនាគមន៍

ផ្លូវសំខាន់ដែលត្រូវប្រើប្រាស់សម្រាប់ដឹកជញ្ជូនសម្ភារៈសំណង់ តាមបណ្តោយផ្លូវជាតិលេខ៤ពីទីក្រុងភ្នំពេញទៅកាន់តំបន់គម្រោងដោយឆ្លងកាត់កណ្តាល កំពង់ស្ពឺ កោះកុង និងខេត្តព្រះសីហនុ។ សកម្មភាពនៃការដឹកជញ្ជូនសម្ភារៈសំណង់នេះបង្កឱ្យប៉ះពាល់ដល់ផ្លូវដែលពាក់ព័ន្ធនឹងគម្រោងដូចជាការខូចខាត ឬការស្ទះចរាចរណ៍។ ភាពកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍អាចកើតឡើងនៅលើផ្លូវជាតិលេខ៤ ដែលបណ្តាលមកពីការបើកល្បឿនលឿននៅចំនុចផ្លូវកោង ឬផ្លូវវាង ឬផ្លូវដែលមានចំណោតខ្លាំង។

វិធានការកាត់បន្ថយ

- ក្រុមហ៊ុនធានាមិនឱ្យមានការខូចខាតផ្លូវ និងការស្ទះចរាចរណ៍ដោយសារការដឹកជញ្ជូនសម្ភារៈសំណង់នោះឡើយ ក្រុមហ៊ុនត្រូវអនុវត្តទៅតាមការកំណត់ទម្ងន់ដឹកជញ្ជូនរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងគោរពទៅតាមពេលវេលាចេញចូលក្នុងទីប្រជុំជន ឬក្រុងសម្រាប់រថយន្តធុនធ្ងន់ទៅតាមការកំណត់អនុញ្ញាតរបស់សាលា ខេត្តដែលរថយន្តឆ្លងកាត់ និងធានាជួសជុលផ្លូវណាដែលខូចខាតដោយសារការដឹកជញ្ជូនរបស់ក្រុមហ៊ុន។
- ផ្តល់សញ្ញាប័ទ្មាប័ចរាចរណ៍/ការសម្រួលចរាចរណ៍ នឹងមានផ្តល់ជូននៅចំនុចផ្លូវប្រសព្វមមាញឹកក្នុងអំឡុងពេលសាងសង់គម្រោង ។
- ក្រុមហ៊ុននឹងផ្តល់ស្លាកសញ្ញាចរាចរណ៍នៅមុខ និងក្រោយការដ្ឋានការងារ/ការដ្ឋានសាងសង់ ដោយយោងតាមច្បាប់ចរាចរណ៍ផ្លូវគោក។

Draft

- អប់រំអ្នកបើកបរគម្រោងសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោកកម្ពុជា និងល្បឿនកំនត់ ចំណុះ និងបើពិសាស្រាមិនត្រូវបើកបរ។
- ការសាងសង់បង្គោល និងធ្វើឡើងនៅរដូវប្រាំង ដើម្បីមានភាពងាយស្រួលក្នុងការដឹកជញ្ជូនគ្រឿងចក្រ និងយានយន្ត ព្រមទាំងទប់ស្កាត់ការខូចខាតផ្លូវ។

៦.៤.៣ ដំណាក់កាលប្រតិបត្តិគម្រោង (Operational Phase)

គម្រោងត្រូវដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធ ដែលមានការប៉ះពាល់ប៉ះពាល់ដល់ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គមដូចខាងក្រោម។

៦.៤.៣.១ ធនធានរូបសាស្ត្រ

ក. សម្លេង និងរំញ័រ

ដោយសារតែការសាងសង់គម្រោងនេះនៅឆ្ងាយពីទីប្រជុំជន និងទីកន្លែងរស់នៅរបស់ប្រជាជន ហេតុនេះការរំខានដោយសម្លេង និងរំញ័រមិនបណ្តាលឱ្យប៉ះពាល់ដល់ប្រជាជនដែលរស់នៅតំបន់នោះទេ។ តែទន្ទឹមនឹងនោះក៏អាចប៉ះពាល់តិចតួចដល់កម្មករដែលធ្វើការនៅក្នុងតំបន់គម្រោងផងដែរ ជាពិសេសចំពោះអ្នកបញ្ជាគ្រឿងចក្រផ្ទាល់ដើម្បីចៀសវាងហេតុប៉ះពាល់ដល់សោតវិញ្ញាណ (Noise-induced hearing loss) ក៏ប៉ុន្តែសម្លេងទាំងអស់នោះមិនអាចជះឥទ្ធិពលខ្លាំងដល់កម្មករដែលធ្វើការនៅតំបន់នោះទេ។ មួយវិញទៀតកម្រិតសម្លេងដែលចេញពីប្រភពគ្រឿងចក្រ ទៅកាន់បរិស្ថានដែលនៅជុំវិញគឺមិនលើសពី ៧៥dB(A)។ ដូចនេះការរំខានដោយសម្លេង និងរំញ័រមិនបានបង្កជាបញ្ហាដល់កម្មករ ឬប្រជាជននោះទេ។

វិធានការកាត់បន្ថយ

- ចំពោះកម្មករត្រូវពាក់ឆ្នុកចុកត្រចៀក (Ears Plug) និង(Ears Muff) ដែលផ្តល់ឱ្យដោយក្រុមហ៊ុន (Personal hearing devices)។

៦.៤.៣.២ ធនធានជីវសាស្ត្រ

ក. ធនធានព្រៃឈើ និងសត្វព្រៃ

នៅដំណើរការបណ្តាញចម្ងាយមានសត្វស្លាប និងប្រជៀវរស់នៅលើដើមឈើ និងតំបន់ព្រៃក្នុងកន្លែងមួយចំនួនក្នុងគន្លងខ្សែបញ្ជូនអគ្គិសនី។ សកម្មភាពហោះហើររបស់សត្វប្រជៀវ/សត្វស្លាប និងការប៉ះពាល់ខ្សែកាប គឺមិនអាចជៀសវាងបានឡើយ។

Draft



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តួយ៉ាងសត្វព្រៃ នឹងរងការប៉ះពាល់ដោយសារដំណើរការគន្លងបញ្ជូនអគ្គិសនី ដោយសារការបាត់បង់ជម្រកដែលបង្កឡើងដោយការកាប់ឆ្ការព្រៃ និងដោយសារការបាត់បង់ជីវិតដែលបណ្តាលមកពីការឆក់អគ្គិសនី។ គ្មានជម្រកសំខាន់ណាមួយត្រូវបានរើចេញឡើយ។ ម្យ៉ាងទៀតមានចំនួនសត្វព្រៃតិចតួចស្ថិតក្នុងតំបន់នៃគម្រោង និងគ្មានប្រភេទសត្វ ដែលស្ថិតក្នុងកម្រិតអភិរក្សខ្ពស់រស់នៅក្នុង តំបន់នៃគម្រោងនេះឡើយ។ ដូច្នេះផលប៉ះពាល់លើសត្វព្រៃមានទំហំតូច។

វិធានការកាត់បន្ថយ

- ក្រុមហ៊ុននឹងកាត់ដើមឈើឱ្យនៅក្រោមបណ្តាញខ្សែបញ្ជូន៣ម៉ែត្រ ដើម្បីរក្សាកម្ពស់ដើមឈើទាបជាង៣ម៉ែត្រ។ ធានាបានថា សត្វស្វាមិនអាចលោតទៅលើដើមឈើទៅកាន់បង្គោលអគ្គិសនីបានទេ។
- តម្លើងអេក្រង់ទប់ស្កាត់សត្វស្វា និងថនិកសត្វទំលើដើមឈើ ដំទៃទៀតពីការឡើងលើបង្គោល កត្តានេះនឹងត្រូវយកមកពិចារណាក្នុងការព្រាងគម្រោងសម្រាប់កន្លែងមួយចំនួនដែលខ្សែបង្គោលគម្រោងឆ្លងកាត់តាមតំបន់ព្រៃ ដែលជាតំបន់ជម្រករបស់សត្វព្រៃដែលអាចឡើងដើមឈើបាន។
- រយៈចន្លោះរវាងឧបករណ៍ចម្លងចរន្តនីមួយៗគឺ ២ម៉ែត្រទៅ២,៥ម៉ែត្រ ដែលរ៉ាប់រងក្នុងការជៀសវាងផលប៉ះពាល់សត្វស្លាបនៅកម្ពុជា។
- កម្មវិធីត្រួតពិនិត្យមួយ នឹងត្រូវបានបង្កើតឡើងក្នុងការកំណត់ការកើតមានឡើងនៃការបាត់បង់របស់សត្វក្នុងដំណើរការ ការតម្លើងបណ្តាញជាមួយនឹងការអនុវត្តវិធានការណ៍សម្រាលក្នុងករណីចាំបាច់។
- ក្រុមហ៊ុនវិនិយោគ នឹងមានវិធានការដាក់ស្លាកសញ្ញាសម្គាល់សម្រាប់សត្វឆ្លងកាត់ក្នុងតំបន់គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនី

៦.៤.៣.៣ ធនធានសេដ្ឋកិច្ច-សង្គម

ក. ទ្រព្យសម្បត្តិប្រជាសហគមន៍

ក្នុងដំណើរការ និងការថែទាំបណ្តាញបញ្ជូន ដីកសិកម្មខ្លះនឹងត្រូវរងផលប៉ះពាល់ក្នុងរយៈពេលខ្លី ហើយដំណាំកសិកម្មមួយចំនួននឹងត្រូវរងការខូចខាត ដោយសារការយកមកប្រើប្រាស់ជាផ្លូវឆ្លងកាត់សម្រាប់ថែទាំបរិក្ខារគម្រោង។ ប៉ុន្តែវាមានរយៈពេលខ្លី និងផលប៉ះពាល់តិចណាស់ ហើយកម្រើតឡើងក្នុងការអនុវត្តជាក់ស្តែង។

វិធានការកាត់បន្ថយ

- ការងារថែទាំបណ្តាញបញ្ជូនក្នុងតំបន់ដីដំណាំកសិផល និងត្រូវបានកំហិតក្នុងកម្រិតតាមដែលអាចធ្វើបានដើម្បីជៀសវាងការរំខានដីកសិកម្ម និងការខូចខាតកសិផល។
- សំណងសម្រាប់ការខាតបង់ ដោយសារការខូចខាតដំណាំកសិផលទាំងឡាយនឹងត្រូវបានផ្តល់ជូន ហើយនឹងយោងទៅតាមតម្លៃទីផ្សារបច្ចុប្បន្ន ក្នុងអំឡុងពេលថែទាំនៅទីកន្លែង។ ការខូចខាតហេដ្ឋារចនាសម្ព័ន្ធនឹងត្រូវបានជុសជុលឡើងវិញ។
- ស្តាប់នគ្រប់គ្រងដីធ្លី និងអាជ្ញាធរមូលដ្ឋានគប្បីមានគម្រោងច្បាស់លាស់ក្នុងការគ្រប់គ្រងដីធ្លី ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចការពារបរិស្ថាន។ ជៀសវាងរាល់ការបំផ្លាញធនធានធម្មជាតិនៅក្នុងតំបន់ជាពិសេសតំបន់ព្រៃឈើ និងជៀសវាងរាល់វិវាទសង្គមធ្ងន់ធ្ងរកើតមានក្នុងតំបន់។

ខ. សុខភាព និងសុខុមាលភាពសាធារណៈ:

ក្នុងកំឡុងពេលដំណើរការប្រព័ន្ធបណ្តាញបញ្ជូន វាអាចមានគ្រោះថ្នាក់ដល់បុគ្គលដែលឡើងលើបង្គោលអគ្គិសនី ឬប៉ះខ្សែកាបអគ្គិសនី (ឧបករណ៍ចម្លងចរន្ត) គម្រោង។ ការឆក់អគ្គិសនីនឹងអាចកើតឡើងដែលជាលទ្ធផលនៃការប៉ះពាល់ឧបករណ៍ចម្លងចរន្តដែលមានចរន្តអគ្គិសនី ការឆេះកើតឡើងចេញពីឧបករណ៍ចម្លងចរន្តទៅកាន់បង្គោល និងការធ្លាយឧបករណ៍ចម្លងចរន្ត។ ប្រជាជនរងការប៉ះពាល់អាចនឹងធ្វេសប្រហោះ ឬជនដែលមិនស្គាល់អត្តសញ្ញាណឡើងទៅកាន់បណ្តាញបញ្ជូនអគ្គិសនី ដែលមានកម្លាំងវ៉ុលខ្លាំង។ ជាពិសេស គឺបណ្តាញបញ្ជូនដែលមានកម្លាំងអគ្គិសនី ២៣០គីឡូវ៉ុល។

វិធានការកាត់បន្ថយ

- ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយ (ស្ថិតនៅឆ្ងាយពីបង្គោល >៣ម៉ែត្រ និង >៣,៥ម៉ែត្រពីឧបករណ៍ចម្លងចរន្ត) និងការចែកខិតប័ណ្ណក្នុងសហគមន៍ដែលមានគម្រោងខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់។
- សម្រាប់បង្គោលអគ្គិសនីដែលនៅក្នុង/ជិតតំបន់ទីប្រជុំជនរបងការពារ និងស្លាកសញ្ញាគ្រោះថ្នាក់សម្រាប់ព្យួរនឹងត្រូវបានផ្តល់ជូន។
- ផ្តល់ជាស្លាកសញ្ញាបម្រាមឱ្យបានគ្រប់គ្រាន់ (រូបភាពគ្រោះថ្នាក់ភ្ជាប់ជាមួយអក្សរ) នៅតាមបង្គោលអគ្គិសនីនីមួយៗនៃគម្រោង និងផ្តល់ការអប់រំដល់ប្រជាជនរស់នៅក្នុងតំបន់អំពីសញ្ញាបម្រាម ដើម្បីធានាថាប្រជាជនបានយល់ដឹងច្បាស់។

Draft



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- ក្រុមហ៊ុននឹងតម្លើងឧបករណ៍កាត់ផ្តាច់អគ្គិសនីស្វ័យប្រវត្តិ ដើម្បីកាត់ផ្តាច់អគ្គិសនីទាន់ពេលវេលា ខណៈមានបង្គោលដួលរលំដោយគ្រោះធម្មជាតិ ដូចជាខ្យល់ព្យុះ ទឹកជំនន់ និងរញ្ជួយដីជាដើម។
- ឧបករណ៍ការពារវន្ទះ និងត្រូវបានតម្លើង ដូចជាខ្សែភ្លើងក្រោមដី ខ្សែចម្លងរាងរង្វង់ និងខ្សែស្រោបដែកឧបករណ៍ចម្លងចរន្ត និងឧបករណ៍ផ្សេងទៀត ដើម្បីទប់ស្កាត់ភាពរអាក់រអួល ដែលបង្កឡើងដោយវន្ទះ។
- រយៈចម្ងាយសុវត្ថិភាពគឺ ៣,៥ ម៉ែត្រ ពីឧបករណ៍ចម្លងចរន្តដែលមានកម្លាំងវ៉ុលត៍ ២៣០ គីឡូវ៉ាត់ បើយោងតាមបទដ្ឋានអគ្គិសនីកម្ពុជា ដែលរួមទាំងលក្ខណៈឧបករណ៍ចម្លងចរន្ត (សីតុណ្ហភាពអតិបរមា មុំយោលអតិបរមារបស់ឧបករណ៍ចម្លងចរន្ត ដោយសារខ្យល់បក់)។

គ. ការកកស្ទះចរាចរណ៍

នៅក្នុងដំណាក់កាលនេះ បង្គោលខ្សែបញ្ជូនអគ្គិសនីនឹងសម្ពោធដាក់ឱ្យប្រើប្រាស់ ហើយកំណើនប្រជាជនក៏អាចកើនឡើងដែរ ព្រោះប្រជាជននឹងបន្តមករស់នៅតំបន់ដែលមានភ្លើងអគ្គិសនី។ ដូចនេះ ការកើនឡើងនូវចំនួនយានយន្តជៀសមិនផុតនោះឡើយ ដែលជាហេតុបង្កឱ្យមានការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍។

ម៉្យាងទៀត ក្នុងអំឡុងពេលដំណើរការគម្រោង ដីប្រើប្រាស់ក្នុងតំបន់នឹងផ្លាស់ប្តូរពីដីកសិកម្មខ្លះទៅជាដីឧស្សាហកម្ម និងពង្រីកតំបន់ក្រុង ដែលនៅតាមបណ្តោយខ្សែបង្គោលបញ្ជូនអគ្គិសនីក្នុងកន្លែងមួយចំនួន។ ការផ្លាស់ប្តូរការប្រើប្រាស់ដីក្នុងតំបន់គម្រោងមិនទាន់អាចធ្វើការសន្និដ្ឋាននៅឡើយទេនាពេលនេះ។

វិធានការកាត់បន្ថយ

- គម្រោងនឹងកំណត់ទិសនៃការធ្វើចរាចរណ៍ឱ្យបានត្រឹមត្រូវ ដោយគោរពតាមច្បាប់ចរាចរណ៍ផ្លូវគោករបស់ប្រទេសកម្ពុជា។
- គម្រោង នឹងដាក់ភ្លើងនិងផ្លាក់សញ្ញាចរាចរណ៍នៅច្រកចេញចូលសំខាន់ៗតាមការគួរឱ្យស្របតាមតម្លើងសញ្ញាចរាចរណ៍របស់រដ្ឋ។
- ហាមឃាត់ការបើកបរចូលទៅតំបន់មួយចំនួន ដែលនៅជិតបង្គោលភ្លើងខ្លាំង ដែលអាចនាំមកភាពគ្រោះថ្នាក់។

ឃ. ការរំខានលើប្រព័ន្ធគមនាគមន៍ (ដោយអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិក)

ខ្សែបញ្ជូនតង់ស្យុងខ្ពស់ អាចធ្វើឱ្យរំខានដល់បរិក្ខារទូរគមនាគមន៍ដោយដែនអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិក។ បាតុភូតទាំងនោះអាចកើតឡើងនៅកន្លែងដែលបណ្តាញបញ្ជូន និង

Draft

ត្រូវបានដំឡើងលើខ្សែទូរស័ព្ទ។ ដែនអេឡិចត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិក ដែលនាំឱ្យមានបញ្ហារំខានជាមួយការសន្ទនាតាមទូរស័ព្ទ ក្នុងអំឡុងពេលផ្ទេរថាមពល។

ដែនអេឡិកត្រូស្តាទិក គឺជាបាតុភូតមួយនៃឧបករណ៍ចម្លងចរន្ត ដែលមានវត្តមានក្នុងតំបន់អេឡិកទ្រិកខាងក្រោមខ្សែបញ្ជូនអគ្គិសនី។ ដូច្នេះភាពខុសគ្នានៃសក្តានុពលអេឡិចទ្រិកកកើតចេញពីចន្លោះវា និងដី ។

វិធានការកាត់បន្ថយ

- ត្រូវធ្វើឱ្យការពិនិត្យអង្កេតសមស្របលើគន្លងខ្សែដែលបានលើកស្នើឡើង ដើម្បីធ្វើឱ្យប្រាកដថាគ្មានបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងបណ្តាញខ្សែទូរស័ព្ទលើអាកាស ឬខ្សែទូរគមនាគមន៍ដទៃទៀត។
- ខ្សែកាបរាងគូទខ្សែង នឹងត្រូវបានប្រើប្រាស់សម្រាប់ខ្សែបញ្ជូន ២៣០គីឡូវ៉ាត់ ដើម្បីកាត់បន្ថយផលប៉ះពាល់។
- គន្លងខ្សែបញ្ជូន នឹងត្រូវបានជ្រើសរើសដើម្បីជៀសវាងការត់កាត់លើខ្សែទូគមនាគមន៍ច្រើនពេក ប្រសិនបើមិនអាចជៀសវាងបាន នោះវិធីសាស្ត្រការពារនឹងត្រូវបានអនុវត្ត ដូចជារក្សាចន្លោះចម្ងាយដោយគោរពតាមបទដ្ឋានបញ្ជូនផ្គត់ផ្គង់អគ្គិសនី ដើម្បីបញ្ចៀសការរអាក់រអួលដោយដែនអេឡិកត្រូស្តាទិក ។

ង. ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

ក្នុងដំណាក់កាលសាងសង់នេះ អាចនឹងប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ក្នុងតំបន់ ដោយសារសកម្មភាពសាងសង់គម្រោង និងការដឹកជញ្ជូនសម្ភារៈបរិក្ខាគ្រឿងចក្រចូលទៅទីតាំងគម្រោង ដូចជាការស្រុត ឬខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវ ដែលមានចំណោទឡើងទូល និងផ្លូវកោងជាដើម។ល។

អាចមានគ្រោះថ្នាក់ចរាចរនៅពេលដែលកំពុងតំឡើងខ្សែភ្លើងកាត់ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ ដោយសារកម្ពស់ខ្សែមិនទាន់បានទាញដល់ចំណុចកម្ពស់ដូចដែលបានគ្រោង ដោយអាចមានការប៉ះពាល់ដល់អ្នកជិះម៉ូតូ កង់ គោយន្ត រថយន្ត ដែលអាចបង្កឱ្យមានរបួសស្នាម ឬគ្រោះថ្នាក់ផ្សេងៗ។

វិធានការកាត់បន្ថយ

ម្ចាស់គម្រោងនឹងឱ្យក្រុមហ៊ុនមៅការ ធ្វើការកែលម្អផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវបណ្តោះអាសន្ន សម្រាប់ចូលទៅសាងសង់គម្រោង ហើយធ្វើការពិភាក្សាជាមួយស្ថាប័នជំនាញក្នុងការដឹងជញ្ជូនសម្ភារធ្ងន់ៗ ដូចជាត្រង់ស្វរ ដែលមានជាដើម។ម្ចាស់គម្រោងនឹងឱ្យអ្នកមៅការ ធ្វើការអប់រំដល់កម្មករដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ហើយក្រុមហ៊ុនត្រូវធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូន និងកំណត់ល្បឿននៃការបើកបរមិនឱ្យលើសពី ៣០គីឡូម៉ែត្រក្នុង១ម៉ោង នៅក្នុងតំបន់ភូមិ និងទីប្រជុំជន ២០គីឡូម៉ែត្រក្នុង១ម៉ោង ដើម្បីបញ្ចៀសគ្រោះថ្នាក់ផ្សេងៗ។

ម្ចាស់គម្រោងនឹងឱ្យអ្នកមៅការ ធ្វើការជូសជុលផ្លូវ ស្ពានដែលមានស្រាប់ដើម្បីធានាលើការដឹកជញ្ជូន និងប្រើប្រាស់គ្រឿងចក្រមិនបង្កឱ្យមានការបាក់ស្ពាន ឬខូចផ្លូវ។

ម្ចាស់គម្រោងនឹងឱ្យអ្នកមៅការ សហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការដោះស្រាយសម្រួលចរាចរក្នុងតំបន់ដែលមានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន និងសំរួលចរាចរនៅពេលដឹកជញ្ជូនត្រង់ស្ទូរ។

ម្ចាស់គម្រោងនឹងឱ្យអ្នកមៅការ ធ្វើទំរន្ទខ្សែឱ្យបានកំពស់៣,៥ម៉ែត្រ យ៉ាងតិចពីខ្នងផ្លូវ នៅពេលដែលធ្វើការអូសតំលើងខ្សែ ហើយត្រូវមានអ្នកប្រចាំការនៅទីនោះផងដែរ។

នៅត្រង់ចំណុចដែលខ្សែនេះឆ្លងកាត់ផ្លូវជាតិ ឬផ្លូវលំ ឬខ្សែតង់ស្យុងមធ្យម ក្រុមហ៊ុននឹងគ្រោងតំលើងកម្ពស់ខ្សែទាប់បំផុតពី១៥ម៉ែត្រ (យោងតាមស្តង់ដាអគ្គិសនី ១៤,២ម៉ែត្រ ឬច្រើនជាងសម្រាប់តង់ស្យុង ២៣០គីឡូវ៉ុល) ហើយទាញឱ្យដល់ក្រិតកំពស់នេះតែម្តង ជៀសវាងគ្រោះថ្នាក់ផ្សេងៗ។

៦.៤.៤ ដំណាក់កាលបញ្ចប់គម្រោង

ក្នុងដំណាក់កាលនេះមិនទាន់មានប៉ះពាល់អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះទេព្រោះសព្វថ្ងៃគម្រោងនេះមិនទាន់បានសាងសង់ឱ្យមានលក្ខណៈពេញលេញនៅឡើយ។

Draft

តារាង៦.២៖ សង្ខេបទំហំនៃហេតុប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន និងវិធានការកាត់បន្ថយ

ហេតុប៉ះពាល់សំខាន់ៗ	ទំហំនៃហេតុប៉ះពាល់				វិធានការកាត់បន្ថយ
	គ្មាន	តិច	មធ្យម	ខ្លាំង	
ដំណាក់កាលរចនាគម្រោង					
សតិអារម្មណ៍ប្រជាសហគមន៍៖ការសិក្សាជ្រើសរើសផ្លូវ សម្រាប់រៀបចំខ្សែបញ្ជូន ដែលដំណឹង និងសកម្មភាព នៃការចុះសិក្សានេះ អាចធ្វើឱ្យមានការប៉ះពាល់ដល់សតិអារម្ម របស់ប្រជាជនសហគមន៍ពីហេតុប៉ះពាល់ ដល់ផ្ទះសម្បែង ដីធ្លី និងផលដំណាំរបស់ពួកគេ។			✓		• ក្រុមហ៊ុនធ្វើការប្រឹក្សាយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធអំពីគោលការណ៍ទូទៅ សម្រាប់កំណត់គន្លងផ្លូវខ្សែបញ្ជូនអគ្គិសនី។ • ក្រុមហ៊ុនធ្វើការផ្សព្វផ្សាយ ដល់ប្រជាជនលើសិនជាទទួលរងការប៉ះពាល់ទៅលើដីធ្លី ដំណាំ និងលំនៅដ្ឋាន នោះគម្រោងនឹងដោះស្រាយជូនតាមតម្លៃទីផ្សារ។ • ការបម្លាស់ទីលំនៅរបស់ពួកគាត់ គឺអាចទិញដីនៅក្នុងតំបន់របស់ពួកគាត់ដដែលតែតម្រូវស្ថិតនៅឆ្ងាយពីតំបន់នៃគន្លងខ្សែបញ្ជូនអគ្គិសនី។
ដំណាក់កាលសាងសង់គម្រោង					
១-ធនធានរូបសាស្ត្រ					
(ក)–សណ្ឋានដី៖ ការឈូសឆាយដីទួល ឬដំបូកខ្ពស់ និងការចាក់បំពេញដីត្រង់តំបន់ទាប ដើម្បីពង្រាបដីឱ្យរាបស្មើ សម្រាប់ធ្វើការសាងសង់ផ្លូវចូលការដ្ឋាន និងទីតាំងសង់បង្គោល។			✓		• ក្រុមហ៊ុនធ្វើការឈូសឆាយដី ទៅតាមលក្ខណៈសណ្ឋានដី សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា។ • ត្រូតពិនិត្យ និងវាយតម្លៃយ៉ាងត្រឹមត្រូវពីមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីកាត់បន្ថយនូវការប្រែប្រួលសណ្ឋានដី។ • ក្រុមហ៊ុនរៀបចំយកអាចម៍ដី ពីទីទួលដែលបានមកពីការឈូសឆាយ ទៅចាក់បំពេញនៅតំបន់ទំនាប ឬកន្លែងដែលមានគ្រលុកធំនៅតំបន់ក្នុងតំបន់គម្រោង ដោយក្រុមហ៊ុនមិនទុកអាចម៍ដីទាំងនោះ ចោលពាសវាលពាសកាលនោះឡើយ។
(ខ)–គុណភាពទឹក និងការចោលសំណល់រឹងរាវ៖ - ការឈូសឆាយដី ដើម្បីសាងសង់បង្គោលភ្លើងដោយសារការ			✓		• ក្រុមហ៊ុនបានយកសំណាកទឹកនៅតាមប្រភពទឹកនីមួយដែលគម្រោង Electrical

Draft

បុកខួងគ្រឹះ ការធ្លាក់កំទេចស៊ីម៉ង់ត៍ ដី និងសំណល់ផ្សេងៗចូលទៅក្នុងទឹក។ - ការចោលសំណល់រឹងដែលមានប្រភពចេញពីសំណល់សម្ភារៈសាងសង់ សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗមកពីការប្រើប្រាស់របស់កម្មករគម្រោង និងការបង្ហូរសំណល់រាវ ពីកន្លែងស្នាក់នៅ ឬពីការហៀរកំពប់សារធាតុប្រេងពីគ្រឿងចក្រ និងរថយន្ត -សំណល់រឹង ជាច្រើនដែលបានមកពីសម្ភារៈសាងសង់ ដូចជាកំណាត់ដែក កំទេចស៊ីម៉ង់ត៍ជាដើម -សំណល់រាវ រួមមានសំណល់ចេញពីការសោងសង់ សំណល់ប្រេង សំណល់ចេញពីការប្រើប្រាស់ទឹក របស់បុគ្គលិកកម្មករសំណង់. និងសំណល់ចេញពីបង្គន់អនាម័យ -ការឈូសឆាយដែលមិនមានផែនការច្បាស់លាស់ ក្នុងការកាត់បន្ថយការហូរច្រោះ. និងសំណឹកដី					power transmission line បានឆ្លងកាត់ទៅពិនិត្យនៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។ • សាងសង់កន្លែងស្តុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវ។ • ពិនិត្យទូវគ្រឿងចក្រមុននឹងចេញប្រតិបត្តិការ ដើម្បីជៀសវាងការជ្រាប ឬលេចប្រេងចេញពីម៉ាស៊ីន។ • ធ្វើការឈូសឆាយដីនៅរដូវប្រាំង។ ក្នុងករណីមានការឈូសឆាយដី រដូវវស្សាក្រុមហ៊ុននឹងប្រតិបត្តិក្នុងទ្រង់ទ្រាយតូច។ • ធ្វើរបាំងការពារកករដី ឬកំទេចកំទីលើចាំបាច់ដើម្បីកុំឱ្យហូរដីចូលទៅក្នុងប្រភពទឹក។ • ធ្វើការអប់រំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងអំពីអនាម័យនៅក្នុងតំបន់សាងសង់ • រៀបចំបទបញ្ជាផ្ទៃក្នុងរបស់ការដ្ឋានសាងសង់ ដោយតម្រូវឱ្យបុគ្គលិក និងកម្មករគោរពយ៉ាងម៉ឺងម៉ាត់ ឬត្រូវទទួលពិន័យយ៉ាងតឹងរឹង • ប្រើប្រាស់បច្ចេកវិទ្យាឈានមុខ និងម៉ាស៊ីនទំនើប (Advanced technology and machinery) • បិទស្លាកបម្រាម (Use warning label) សម្រាប់សម្គាល់ចំពោះសម្ភារៈដែលមានជាតិពុល និងគ្រោះថ្នាក់ធ្ងន់ធ្ងរ។
(ក)–គុណភាពខ្យល់៖ -សកម្មភាពឈូសឆាយដី -ការប្រើប្រាស់គ្រឿងយន្ត ការបុក/ខួងគ្រឹះ ការប្រើប្រាស់ម្ជាំលាប ការប្រើប្រាស់ប្រេងឥន្ធនៈ និងការបោះចោលសំណល់រឹង-ការធ្វើឱ្យមានធូលី សារធាតុគីមី និងក្លិនស្អុយ សាយភាយចេញ			✓		• អនុវត្តន៍ជាប្រចាំចំពោះការត្រួតពិនិត្យមើលម៉ាស៊ីន គ្រឿងចក្រ និងឧបករណ៍នានា ។ • សេវាកម្មថែរក្សាការពារ ជាទៀងទាត់នៃគ្រឿងចក្រ និងឧបករណ៍សាងសង់ ត្រូវអនុវត្តន៍ឱ្យបានតឹងរឹង។ • សំណល់នៃសម្ភារៈសាងសង់នៅក្នុងការដ្ឋានត្រូវច្រកចូលទៅក្នុងការ៉ុង/បាវ • បាញ់ស្រោចទឹកនៅក្នុងតំបន់សាងសង់ និង

Draft

ទៅបរិយាកាស និងសកម្មភាពការប្រើប្រាស់ម៉ាស៊ីនភ្លើង					នៅផ្លូវទៅកាន់តំបន់សាងសង់។ • ប្រើប្រាស់គ្រឿងចក្រថ្មីៗ ដែលមិនមានការបញ្ចេញផ្សែងពុល ទៅលើខ្យល់/បរិយាកាស។ • នៅពេលមានការរិះគន់ពីធូលី និងឧស្ម័នពីសំណាក់ប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវ ចូលតំបន់គម្រោង នោះក្រុមហ៊ុនត្រូវធ្វើការត្រួតពិនិត្យ។
(ឃ)-ការរំខានដោយសម្លេង និងរំញ័រ៖ - សកម្មភាពរបស់គ្រឿងចក្រ - ការបុកគ្រឹះបង្ហាប់ដី - ម៉ាស៊ីនភ្លើង			✓		• គ្រឿងទប់សម្លេងដូចជា ឧបករណ៍កាត់បន្ថយសម្លេង (sound absorbtion)។ • រាល់សកម្មភាពសាងសង់ ដែលបង្កើតឱ្យមានកម្រិតសម្លេងខ្លាំង លើសពី៨៥ ដេស៊ីបែល ក្រុមហ៊ុនត្រូវកំណត់ពេលវេលាឱ្យមានតែនៅពេលថ្ងៃប៉ុណ្ណោះ (០៦:០០ ព្រឹក ដល់០៦:០០ល្ងាច)។ • ចំពោះបុគ្គលិក-កម្មករដែលប្រឈមទៅនឹងសម្លេងខ្លាំង និងមានរយៈពេលយូរ ត្រូវពាក់ឆ្នុកចុកត្រចៀក (Ears Plug) និង(Ears Muff) ដែលផ្តល់ឱ្យដោយក្រុមហ៊ុន (Personal hearing devices)។ • ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងចក្រ ព្រមទាំងម៉ាស៊ីនភ្លើងធុនទំនើប ដែលបញ្ចោញសម្លេងតិចមិនឱ្យប៉ះពាល់ ដល់សុខភាពរបស់បុគ្គលិក-កម្មករ ។ • កម្រិតសម្លេងចេញពីប្រភពគ្រឿងចក្រ នៅក្នុងចម្ងាយ១០០ម៉ែត្រ ទៅកាន់បរិស្ថានដែលនៅជុំវិញគឺមិនលើសពី៧៥dB(A) នៅពេលថ្ងៃ។
(ង)-ប្រព័ន្ធផ្លូវទឹក៖ -អាចនឹងមានការកកស្ទះផ្លូវទឹកតាមកូនអូរតូចៗ ដែលអ្នកមៅការសាងសង់ផ្លូវចូល ក្នុងគោលបំណងសាងសង់ បង្គោល			✓		• ម្ចាស់គម្រោងត្រូវតម្រូវឱ្យ អ្នកមៅការសម្អាតទីតាំង រួមមានការកាយសម្អាតផ្លូវទឹកដែលខ្លួនបានបិទធ្វើផ្លូវចូលសាងសង់បង្គោលភ្លើងរបស់គម្រោងនេះ។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

(ច)-ការហូរច្រោះ និងគុណភាពដី៖ -អាចមានការហូរច្រោះ ជញ្ជាំងរណ្តៅដី ឬគំនរអាចម៍ដី ដែលធ្វើឱ្យល្អក់ទឹកខ្លាំង នៃប្រភពទឹកនៅក្បែរនោះ -ការចាក់ដី បំពេញលើកកម្ពស់នៅតំបន់តាមជើងបង្គោល ឬអនុស្ថានីយ៍ ដែលជាពិសេសតំបន់វាលស្រែជុំវិញ ហើយនៅរដូវភ្លៀងមានការហូរច្រោះដីនេះ ទៅគ្របលើដីស្រែ			✓		• ត្រូតពិនិត្យអ្នកមៅការសាងសង់ជាប្រចាំ នូវជញ្ជាំងរណ្តៅដី ឬគំនរអាចម៍ដីដោយយោងតាមឯកសារ នៃកិច្ចសន្យាការងារ ហើយត្រូវកាយលុបរណ្តៅគ្រឹះ និងពង្រាបដីឱ្យដូចដើមវិញ។ • ការសាងសង់គម្រោងនេះភាគច្រើន គឺត្រូវបានអនុវត្តន៍នៅរដូវប្រាំង ដែលមានការប៉ះពាល់ដល់ផ្នែកនេះតិចតួចបំផុត។
(ឆ)-ការបំពុលដី៖ -ការជីករណ្តៅបង្គោល ការគរអាចម៍ដីមិនបានល្អ ការគ្រប់គ្រងការងារក្នុងការចាក់គ្រឹះមិនបានល្អ (ការកំពប់ស៊ីម៉ង់ត៍ ទឹកស៊ីម៉ង់ត៍ ជាដើម) -ការគ្រប់គ្រងសំណល់រឹង ឬសំណង់រាវមិនបានល្អ នៅការដ្ឋាន កន្លែងស្នាក់នៅបុគ្គលិក រោងជាងឈ្លាំង			✓		• ត្រូតពិនិត្យអ្នកមៅការសាងសង់ជាប្រចាំ ត្រូវពិនិត្យរណ្តៅ និងគំនរអាចម៍ដី។ • ត្រូតពិនិត្យមើលកន្លែងលាយ និងចាក់បេតុង កន្លែងលាងថ្ម ដោយជឿជាក់ថាមិនមានការបំពុលដី ក្នុងតំបន់គម្រោងនោះឡើយ។ • ក្នុងករណី មានការលេចធ្លាយប្រេងលើសពី១.០០០លីត្រ ម្ចាស់គម្រោងត្រូវមានវិធានការជាបន្ទាន់ ដោយមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថានប័នជំនាញពាក់ព័ន្ធ ដើម្បីយកប្រេង ដែលកំពប់ និងកើបយកដីដែលប្រេងហូរលើ នោះចេញ ហើយទុកដាក់វាឱ្យមានសុវត្ថិភាព និងរក្សាគម្លាតឱ្យឆ្ងាយពីប្រភពទឹក។ • អប់រំដល់កម្មករក្នុងការបោះបង់សំណល់រឹង ឬរាវ ជាពិសេសការកំពប់ប្រេងឥន្ធៈ ដែលអាចធ្វើឱ្យខូចគុណភាពទឹក និងគុណភាពដីក្នុងគម្រោង។

Draft

(ជ)-ការគ្រប់គ្រងសំណល់អាចម៍ដី៖ -សណ្ដានដី អាចមានលក្ខណៈប្រែប្រួលតិចតួច នៅក្នុងតំបន់ដែល សាងសង់បង្គោលភ្លើង ត្រង់តំបន់ដែលចាក់ដី លើកកម្ពស់ និងព្រមទាំងមានការ ឈូឆាយដីទៅតាម លក្ខណៈសណ្ដានដីដែលជា ហេតុបង្កឱ្យមានផលប៉ះពាល់ និងមានគំនរអាចម៍ដីនេះកើតឡើង			✓		• ក្រុមហ៊ុនរៀបចំយកអាចម៍ដី ពីទីទួលដែលបានមកពីការឈូសឆាយ ទៅចាក់បំពេញនៅតំបន់ទំនាប ឬកន្លែងដែលមានគ្រលុកធំ នៅក្នុងតំបន់គម្រោង។ ជាពិសេសក្រុមហ៊ុនលុបរណ្ដៅ និងពង្រាបដីហើយសម្អាតទីតាំងទាំងនោះឱ្យស្អាតដូចដើមវិញដើម្បីរក្សាឱ្យបាននូវទម្រង់សណ្ដានដី។
២-ធនធានជីវសាស្ត្រ					
ក-ធនធានព្រៃឈើ និងជម្រករបស់សត្វ៖ - ធនធាន ព្រៃឈើមានការបាត់បង់ ដោយការកាប់សម្អាតត្រង់ចំនុច ដែលត្រូវសាងសង់បង្គោលខ្សែបញ្ជូន - បញ្ហាភ្លើងឆេះព្រៃ			✓		• ការកាប់ព្រៃឈើ ត្រូវធ្វើឡើងក្នុងដែនកំណត់ សម្រាប់តែតម្រូវការទីកន្លែងការសាងសង់ និងនៅសងខាងបណ្ដាញខ្សែកាបចម្ងាយ៣០ម៉ែត្រប៉ុណ្ណោះ ។ • ក្រុមហ៊ុនថែរក្សាប្រភេទឈើ ឬបណ្ដុំព្រៃដែលមានលក្ខណៈបច្ចេកទេសសម្រាប់ជីវៈចម្រុះការពារបរិស្ថាន ព្រៃឈើនៅលើភ្នំ និងទីជម្រាលមាត់ ស្ទឹងព្រែក និងតំបន់អភិរក្ស។ • ក្រុមហ៊ុននឹងអនុវត្តទៅតាមដែនការមេក្រុមហ៊ុន និងសុំការអនុញ្ញាតពីក្រសួងបរិស្ថានទៅតាមនីតិវិធីច្បាប់ជាធរមាន។ • ដើមឈើទាំងអស់នៅក្នុងទីតាំងគម្រោង ដែលត្រូវបានកាប់សម្រាប់គោលបំណងនៃសិទ្ធិប្រើប្រាស់ទីតាំងដែលត្រូវសាងសង់តែប៉ុណ្ណោះ។ • ក្រុមហ៊ុននឹងធ្វើការពិន័យ ឬបញ្ឈប់ពីការងារដល់កម្មករណា ដែលកាប់ដើមឈើដោយ ពុំមានការអនុញ្ញាតជាមុនពីអ្នកគ្រប់គ្រងគម្រោង។ • ធ្វើការអប់រំណែនាំដល់ កម្មករទាំងអស់របស់ក្រុមហ៊ុន ឱ្យមានការប្រុងប្រយ័ត្ន

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

					ចំពោះការបង្កាត់ភ្លើងសម្រាប់គោលបំណងផ្សេងៗ។ • ក្រុមហ៊ុនបំពាក់ឧបករណ៍បង្ការ គ្រោះអគ្គីភ័យតំបន់ក្នុងតំបន់ការដ្ឋាន។ • ក្រុមហ៊ុន នឹងដាក់ស្លាកសញ្ញាសម្គាល់សម្រាប់សត្វឆ្លងកាត់ក្នុងតំបន់ព្រៃ។
(ខ)-ព្រៃការពារ/តំបន់ការពារ៖ -មានការប៉ះពាល់បន្តិចបន្តួចលើព្រៃការងារក្បាលឆាយ ប្រវែងសរុប១.៨៥០ម៉ែត្រ ដែលនាំឱ្យមានការប៉ះពាល់ ដល់អេកូឡូស៊ីខ្លះៗ ជាពិសេសពពួកត្រី និងបក្សី			✓		• ការសាងសង់គម្រោងនៅតំបន់នេះ ត្រូវធ្វើការដោយប្រុងប្រយ័ត្ន ដូចជាការងារដី ការងារបេតុង ការងារគ្រឹះ ត្រូវគោរពតាមបទដ្ឋានបច្ចេកទេស ត្រូវធ្វើឡើងតែនៅរដូវប្រាំងតែប៉ុណ្ណោះ។ • ពេលសាងសង់ ចប់ត្រូវលុបរណ្តៅគ្រឹះភ្លាមដោយធ្វើការបង្ហាប់ដីឱ្យបានត្រឹមត្រូវ។ • ត្រូវមានការរៀបចំគ្រប់គ្រងសំណល់រឹង-រាវឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពជាពិសេស មិនឱ្យមានការបំពុលបរិស្ថានក្នុងតំបន់ព្រៃការពារនេះ។
គ-ពពួកសត្វព្រៃ៖ - ធនធានសត្វព្រៃនឹងថយចុះឬងាប់ ឬបម្លាស់ទីទៅរកកន្លែងផ្សេង - រំខានដល់ការបន្តពូជរបស់សត្វដោយសារសម្លេង និងរំញ័រ របស់គ្រឿងចក្រ - ភ្លើងឆេះព្រៃ			✓		• ឈូសឆាយទៅតាមប្លង់មេ ដោយបង្កលក្ខណៈងាយស្រួលដល់ ការបម្លាស់ទីរបស់សត្វ។ • កំណត់ពេលវេលាធ្វើការតែពេលថ្ងៃ • ដាំដើមឈើ និងរុក្ខជាតិឡើងវិញ • ដាក់ពិន័យដល់កម្មករដែលបរបាញ់សត្វព្រៃ • គ្រប់គ្រងយ៉ាងណា កុំឱ្យមានបទល្មើសសត្វព្រៃនានា ដែលកើតឡើងនៅក្នុងតំបន់នេះ ដោយសហការ ជាមួយនឹងឧទ្យានុរក្សនៃឧទ្យានជាតិជាប្រចាំ។ • ក្រុមហ៊ុន នឹងដាក់ស្លាកសញ្ញាសម្គាល់សម្រាប់សត្វឆ្លងកាត់ក្នុងតំបន់ព្រៃដែលមានការសាងសង់បង្គោលអគ្គិសនី។

Draft

๓-ឆនឆានសេដ្ឋកិច្ច-សង្គម					
(ក)- ទ្រព្យសម្បត្តិប្រជាសហគមន៍៖ -ទីតាំងសាងសង់បង្គោល នឹងអាចប៉ះពាល់ដល់ដីលំនៅដ្ឋាន ដីស្រែ ចម្ការ ដើមឈើហូបផ្លែរបស់ប្រជាជន			✓		• ការកាប់ដើមឈើ នឹងត្រូវធ្វើឡើងក្នុងតំបន់ទីតាំងគម្រោង ដែលត្រូវការសាងសង់បង្គោល និងក្រោមគន្លងតែប៉ុណ្ណោះ។ • ការផ្លាស់គ្រឹះបង្គោល និងការតម្រង់បណ្តាញ/ ផ្លូវបញ្ជូនអគ្គិសនីដើម្បីបញ្ចៀសការកាប់ព្រៃឈើ និងឈើហូបផ្លែដែលតម្រូវឱ្យធ្វើឡើងក្នុងកន្លែងខ្លះ។ • ដាំដើមឈើឡើងវិញ ក្នុងចំនួនដើមឈើដែលបានបាត់បង់ក្នុងពេលជាក់លាក់។ • ប្រភេទហូបផ្លែដែលមានកម្ពស់ទាបជាង ៣ ម៉ែត្រ ដែលមានទីតាំងក្រោមបរិវេណដែលប៉ះពាល់នឹងទុកឱ្យដុះតាមធម្មតា។ • ក្រុមហ៊ុនប្រតិបត្តិ នឹងចរចារជាមួយម្ចាស់ចម្ការ ដើម្បីដោះស្រាយការខូចខាតដំណាំកសិផល និងដើមឈើហូបផ្លែ។ • តម្រូវឱ្យមានសំណង ចំពោះការខូចខាតដើមឈើហូបផ្លែ និងដំណាំកសិផលរបស់សហគមន៍ ដោយសារសកម្មភាពសាងសង់គម្រោង។
(ខ)-សុខភាព និងសុខុមាលភាពសាធារណៈ៖ - ការប្រើប្រាស់ទឹកមិនស្អាត - ការទុកដាក់សំណល់មិនបានត្រឹមត្រូវ - ការមានគ្រោះថ្នាក់ ឬរបួសបណ្តាលមកពីសកម្មភាពសាងសង់។			✓		• ផ្គត់ផ្គង់ទឹកន្លែងស្នាក់នៅសមរម្យ និងទឹកស្អាតដល់កម្មករ។ • តម្រូវការទឹកស្អាតសម្រាប់ប្រើប្រាស់ នៅពេលកំពុងសាងសង់ គឺចាំបាច់ណាស់រួមទាំងទឹកសម្រាប់បរិភោគ និងការលាងសម្អាតរាងកាយប្រចាំថ្ងៃ។ • សាងសង់បង្គន់បណ្តោះអាសន្នដោយគោរពទៅតាមស្តង់ដារអនាម័យត្រឹមត្រូវ • ធ្វើការអប់រំកម្មករ និងប្រជាជនក្នុងមូលដ្ឋានដែលរស់នៅក្បែរការដ្ឋានគម្រោង ឱ្យយល់ដឹងអំពីជម្ងឺកាមរោគ-អេដស៍ និងវិធីការពារ • ដើម្បីធ្វើការពិនិត្យពិគ្រោះព្យាបាល ដល់កម្មករ និងសង្គ្រោះបន្ទាន់ក្នុងករណីដែលមានជម្ងឺ ឬរបួសធ្ងន់ធ្ងរជាយថាហេតុ។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

					• ប្រកាន់យកសុវត្ថិភាពជាចម្បងនៅការដ្ឋានសាងសង់ (Safety first)។ • គម្រោងនឹងបណ្តោះបណ្តាលកម្មករពីសុវត្ថិភាពនៃការធ្លាក់ពីទីខ្ពស់ និងផ្តល់នូវខ្សែ ក្រវ៉ាត់ការពារសម្រាប់កម្មករ ដែលឡើងទៅធ្វើការនៅទីខ្ពស់ ជាពិសេសលើឧបករណ៍ស្ងួច ឬបង្គោលអគ្គិសនី។ • ហាមមិនឱ្យអ្នកគ្មានភារកិច្ចចូលក្នុងការដ្ឋានសាងសង់ ដោយការដាក់ស្លាកសញ្ញាហាមឃាត់ជាដើម។ • គម្រោង នឹងមានការប្រើប្រាស់ម៉ាស៊ីនថ្មី។ និងមាន បំពាក់ឧបករណ៍កាត់បន្ថយសម្លេង និងផ្សែង ឱ្យស្របតាមបទដ្ឋាននៃការបញ្ចេញសម្លេង និងគុណភាពខ្យល់ របស់ក្រសួងបរិស្ថាន ។
(គ)-គមនាគមន៍៖ -ផ្លូវសំខាន់ ដែលត្រូវប្រើប្រាស់សម្រាប់ ដឹកជញ្ជូនសម្ភារៈសំណង់ តាមបណ្តោយផ្លូវជាតិលេខ៤ ពីទីក្រុងភ្នំពេញទៅកាន់តំបន់គម្រោង			✓		• ក្រុមហ៊ុនធានាមិនឱ្យ មានការខូចខាតផ្លូវ និងការស្ទះចរាចរណ៍ ដោយសារការដឹកជញ្ជូនសម្ភារៈសំណង់នោះឡើយ ក្រុមហ៊ុនត្រូវអនុវត្តទៅតាមការកំណត់ ទម្ងន់ដឹកជញ្ជូន របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។ • ផ្តល់សណ្តាប់ធ្នាប់ចរាចរណ៍/ ការសម្រួលចរាចរណ៍ នឹងមានផ្តល់ជូននៅចំនុចផ្លូវប្រសព្វមមាញឹក ក្នុងអំឡុងពេលសាងសង់គម្រោង ។ • ក្រុមហ៊ុន នឹងផ្តល់ស្លាកសញ្ញាចរាចរណ៍នៅមុខ និងក្រោយការដ្ឋានការងារ/ការដ្ឋានសាងសង់ ដោយយោងតាមច្បាប់ចរាចរណ៍ផ្លូវគោក។ • អប់រំអ្នកបើកបរគម្រោង សណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោកកម្ពុជា នឹងល្បឿនកំនត់ចំណុះ និងលើពិសាស្រាមិនបើកបរ។ • ការសាងសង់បង្គោល និងធ្វើឡើងនៅរដូវប្រាំង ដើម្បីមានភាពងាយស្រួលក្នុងការដឹក

Draft

					ជញ្ជូនគ្រឿងចក្រ និងយានយន្ត ព្រមទាំងទប់ស្កាត់ការខូចខាតផ្លូវ។
ដំណាក់កាលប្រតិបត្តិគម្រោង					
១-ធនធានរូបសាស្ត្រ					
(ក) សម្លេង និងរំញ័រ៖ -មានកម្រិតគួចណាស់ ដែលនឹងអាចកើតមានឡើង នៅពេលចល័តគ្រឿងចក្រ ជួសជុលតែប៉ុណ្ណោះ។			✓		• រាល់សកម្មភាពសាងសង់ និងជួសជុលដែលបង្កើតឱ្យមាន កម្រិតសម្លេងខ្លាំងលើសពី៨៥ដេស៊ីបែល ក្រុមហ៊ុនត្រូវកំណត់ពេលវេលា ឱ្យមានតែនៅពេលថ្ងៃប៉ុណ្ណោះ (០៦:០០ ព្រឹក ដល់ ០៦:០០ល្ងាច) ដើម្បីជៀសវាងការរំខាន ដោយសម្លេងទៅដល់ការរស់នៅរបស់ប្រជាជន ដែលនៅក្បែរនោះ។ • ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងចក្រ ទំនើបដែលបញ្ចោញសម្លេងតិច ។
២-ធនធានជីវសាស្ត្រ					
(ក)-ធនធានព្រៃឈើ និងសត្វព្រៃ៖ -សកម្មភាពហោះហើរ របស់សត្វប្រជៀវ/សត្វស្លាប និងការប៉ះពាល់ខ្សែកាប គឺមិនអាចជៀសវាងបានឡើយ -សត្វព្រៃ នឹងរងការប៉ះពាល់ដោយសារដំណើរការគន្លងខ្សែបញ្ជូនអគ្គិសនី ដោយសារការបាត់បង់ជម្រកដែលបង្ក ឡើងដោយការកាប់ឆ្ការព្រៃ និងដោយសារការបាត់បង់ជីវិត ដែលបណ្តាលមកពីការឆក់អគ្គិសនី			✓		• ក្រុមហ៊ុននឹងកាត់ដើមឈើ ឱ្យនៅក្រោមបណ្តាញបញ្ជូន ៣ម៉ែត្រ ដើម្បីរក្សាកម្ពស់ដើមឈើទាបជាង៣ម៉ែត្រ។ • តម្លើងអេក្រង់ទប់ស្កាត់សត្វស្លា និងថនិកសត្វ ទំលើដើមឈើ ដទៃទៀតពីការឡើងលើបង្គោល កត្តានេះនឹងត្រូវយកមកពិចារណាក្នុងការព្រាងគម្រោង សម្រាប់កន្លែងមួយចំនួនដែលខ្សែបង្គោលគម្រោងឆ្លងកាត់តាមតំបន់ព្រៃ ដែលជាតំបន់ជម្រករបស់សត្វព្រៃ ដែលអាចឡើងដើមឈើបាន។ • រយៈចន្លោះរវាងឧបករណ៍ចម្លងចរន្តនីមួយៗ គឺ ២ម៉ែត្រ ទៅ ២,៥ ម៉ែត្រ ដែលវ៉ាប់រងក្នុងការជៀសវាងផលប៉ះពាល់សត្វស្លាប នៅកម្ពុជា។ • កម្មវិធីត្រួតពិនិត្យមួយ នឹងត្រូវបានបង្កើតឡើងក្នុងការកំណត់ការកើតមានឡើង នៃការបាត់បង់របស់សត្វ ក្នុងដំណើរការការតម្លើងបណ្តាញជាមួយនឹងការអនុវត្តវិធានការសម្រាលក្នុងករណីចាំបាច់។

Draft



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

					• ក្រុមហ៊ុនវិនិយោគនឹងមានវិធានការដាក់ស្លាកសញ្ញាសម្គាល់សម្រាប់សត្វឆ្លងកាត់
៣-ធនធានសេដ្ឋកិច្ច-សង្គម					
(ក)-ទ្រព្យសម្បត្តិប្រជាសហគមន៍៖ -ដីកសិកម្មខ្លះ នឹងត្រូវរងផលប៉ះពាល់ក្នុងរយៈពេលខ្លី ហើយដំណាំកសិកម្មមួយចំនួននឹងត្រូវរងការខូចខាត ដោយសារការយកមកប្រើប្រាស់ជាផ្លូវឆ្លងកាត់សម្រាប់ថែទាំបរិក្ខារគម្រោង។			✓		• ការងារថែទាំបណ្តាញបញ្ជូនក្នុងតំបន់ដីដំណាំកសិផល និងត្រូវបានកំហិតក្នុងកម្រិត តាមដែលអាចធ្វើបាន។ • សំណងសម្រាប់ការខាតបង់ ដោយសារការខូចខាតដំណាំកសិផលទាំងឡាយនឹងត្រូវបានផ្តល់ជូន។ • ស្តាប័នគ្រប់គ្រងដីធ្លី និងអាជ្ញាធរមូលដ្ឋានគប្បីមានគម្រោងច្បាស់លាស់ក្នុងការគ្រប់គ្រងដីធ្លី ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចការពារបរិស្ថាន។
(ខ)-សុខភាព និងសុខុមាលភាពសាធារណៈ៖ -ការឆក់អគ្គិសនី			✓		• ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយ (ស្ថិតនៅឆ្ងាយពីបង្គោល >៣ម៉ែត្រ និង >៣,៥ម៉ែត្រពីឧបករណ៍ចម្លងចរន្ត) និងការចែកខិតប័ណ្ណក្នុងសហគមន៍ដែលមានគម្រោងខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់។ • សម្រាប់បង្គោលអគ្គិសនីដែលនៅក្នុង/ជិតតំបន់ទីប្រជុំជនធ្វើរបងការពារ និងស្លាកសញ្ញាគ្រោះថ្នាក់សម្រាប់ព្យួរ នឹងត្រូវបានផ្តល់ជូន។ • ផ្តល់ជាស្លាកសញ្ញាបម្រាមឱ្យបានគ្រប់គ្រាន់ (រូបភាពគ្រោះថ្នាក់ភ្ជាប់ជាមួយអក្សរ) នៅតាមបង្គោលអគ្គិសនីនីមួយៗ • ក្រុមហ៊ុននឹងតម្លើងឧបករណ៍កាត់ផ្តាច់អគ្គិសនីស្វ័យប្រវត្តិដើម្បីកាត់ផ្តាច់អគ្គិសនីទាន់ពេលវេលា ខណៈមានបង្គោលដួលរលំដោយគ្រោះធម្មជាតិ ដូចជាខ្យល់ព្យុះ ទឹកជំនន់ និងរញ្ជួយដីជាដើម។ • ឧបករណ៍ការពារនេះ និងត្រូវបានតម្លើងដូចជាខ្សែភ្លើងក្រោមដី ខ្សែចម្លងរាងរង្វង់ និងខ្សែស្រោបដែកឧបករណ៍ចម្លងចរន្ត។

Draft

					• រយៈចម្ងាយសុវត្ថិភាពគឺ ៣,៥ម៉ែត្រពីឧបករណ៍ចម្លងចរន្តដែលមានកម្លាំងវ៉ុល ២៣០គីឡូវ៉ាត់។
(គ)-ការកកស្ទះចរាចរណ៍៖ -កំណើនប្រជាជន -ការកើនឡើងនូវចំនួនយានយន្ត			✓		• គម្រោង នឹងកំណត់ទិសនៃការធ្វើចរាចរណ៍ឱ្យបានត្រឹមត្រូវ ដោយគោរពតាមច្បាប់ចរាចរណ៍ផ្លូវគោករបស់ប្រទេសកម្ពុជា។ • គម្រោង នឹងដាក់ភ្លើងនិងផ្លាក់សញ្ញាចរាចរណ៍នៅច្រកចេញចូលសំខាន់ៗតាមការគួរឱ្យស្របតាមភ្លើងសញ្ញាចរាចរណ៍របស់រដ្ឋ។ • ហាមឃាត់ការបើកបរចូល ទៅតំបន់មួយចំនួន ដែលនៅជិតបង្គោលភ្លើងខ្លាំង ដែលអាចនាំមកភាពគ្រោះថ្នាក់
(ឃ)-ការរំខានលើប្រព័ន្ធទូរគមនាគមន៍ (ដោយអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិក)			✓		• ត្រូវធ្វើ ឱ្យការពិនិត្យអង្កេតសមស្របលើគន្លងខ្សែដែលបានលើកស្ទើឡើង ដើម្បីធ្វើឱ្យប្រាកដ ថាគ្មានបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងបណ្តាញខ្សែទូរស័ព្ទលើអាកាស ឬខ្សែទូរគមនាគមន៍ដទៃទៀត។ • ខ្សែកាបរាងគូទខ្សែង នឹងត្រូវបានប្រើប្រាស់សម្រាប់ខ្សែបញ្ជូន ២៣០គីឡូវ៉ុលដើម្បីកាត់បន្ថយផលប៉ះពាល់។ • គន្លងខ្សែបញ្ជូន នឹងត្រូវបានជ្រើសរើសដើម្បីជៀសវាងការរត់កាត់លើខ្សែទូរគមនាគមន៍ច្រើនពេក។
(ង)-ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ៖ -ដោយសារសកម្មភាពសាងសង់គម្រោង និងការដឹកជញ្ជូនសម្ភារៈបរិក្ខារគ្រឿងចក្រ			✓		• ក្រុមហ៊ុនមៅការ ធ្វើការកែលំអផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវបណ្តុះអាសន្នសម្រាប់ចូលទៅសាងសង់គម្រោង។ • ម្ចាស់គម្រោងនឹងឲ្យអ្នកមៅការ ធ្វើការជួសជុលផ្លូវស្ពានដែលមានស្រាប់។ • ម្ចាស់គម្រោងនឹងឲ្យអ្នកមៅការ សហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការដោះស្រាយសម្រួលចរាចរក្នុងតំបន់ដែលមានការកកស្ទះ។ • ម្ចាស់គម្រោងនឹងឲ្យអ្នកមៅការ ធ្វើទម្រង់ខ្សែឲ្យបានកម្ពស់៣,៥ម៉ែត្រ យ៉ាងតិចពី

Draft

					ខ្នងផ្លូវនៅពេលដែលធ្វើការអូសតម្លើងខ្សែ។ • នៅត្រង់ចំណុចដែលខ្សែនេះឆ្លងកាត់ផ្លូវជាតិ ឬផ្លូវលំ ឬខ្សែតង់ស្យុងមធ្យម ក្រុមហ៊ុននឹងគ្រោងតម្លើងកម្ពស់ខ្សែទាបបំផុតពី ១៥ម៉ែត្រ។

៦.៥ ពិពណ៌នាហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមវិជ្ជមាន

ដោយផ្អែកទៅលើទំហំនៃសកម្មភាពរបស់គម្រោងជាទូទៅ នៅក្នុងដំណាក់កាលនៃប្រតិបត្តិគម្រោងនេះមានហេតុប៉ះពាល់បរិស្ថាន និងសង្គមវិជ្ជមានដោយសារតែគម្រោងខ្សែបញ្ជូនអគ្គិសនីនេះ បានចូលរួមចំណែកក្នុងការជំរុញការអភិវឌ្ឍន៍ប្រទេសជាតិ។ គម្រោងខ្សែបញ្ជូនអគ្គិសនីនេះបានអត្ថប្រយោជន៍ដល់សង្គមជាតិតាមរយៈ ផ្តល់ការងារធ្វើ កាត់បន្ថយចំណាកស្រុកទៅក្រៅប្រទេស ផ្តល់ថាមពលអគ្គិសនីប្រើប្រាស់ កើនឡើងការវិនិយោគ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

៦.៥.១ មុខរបរ និងប្រាក់ចំណូល

→ នៅក្នុងដំណាក់កាលសាងសង់អាចមានប្រជាជនមួយចំនួន ត្រូវបានជ្រើសរើសឱ្យធ្វើជាកម្មករសំណង់ទៅតាមកម្រិតមុខជំនាញរបស់ពួកគេ។

→ ងាយស្រួលក្នុងប្រកបមុខរបររកស៊ី ព្រោះនៅពេលមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ប្រជាជនអាចលក់ដូរដល់ពេលយប់ អាចធ្វើដំណើរនៅពេលយប់បាន ការលក់ដូរកើនចំណែនជាងមុន។

៦.៥.២ ការកាត់បន្ថយចំណាកស្រុកទៅក្រៅប្រទេស

→ គម្រោងនេះនឹងបង្កើតការងារ ដល់ប្រជាជននៅក្នុង តាមបណ្តាខេត្តនានា ដោយបានជួយកាត់បន្ថយចំណាកស្រុកទៅធ្វើជាកម្មករនៅក្រៅប្រទេស ដែលនេះបានផ្តល់ជាប្រយោជន៍សម្រាប់រាជរដ្ឋាភិបាលក្នុងការធ្វើផែនការគ្រប់គ្រង និងអភិវឌ្ឍន៍។

៦.៥.៣ ផ្តល់ថាមពលអគ្គិសនីប្រើប្រាស់

→ គម្រោងនេះនឹងផ្តល់ថាមពលអគ្គិសនី ដែលផលិតដោយធ្យូងថ្ម សម្រាប់បំពេញតម្រូវការប្រើប្រាស់អគ្គិសនីដល់ប្រជាជនបានគ្រប់គ្រាន់ និងប្រសើរជាមុន។

→ គម្រោងនេះនឹងផ្តល់ថាមពលអគ្គិសនីជូនដល់ប្រជាជនជុំវិញ រាជធានីភ្នំពេញដែលមិនទាន់មានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ផងដែរ។

Draft



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៦.៤.៤ ការកើនឡើងនូវការវិនិយោគ

→ គម្រោងខ្សែបញ្ជូនអគ្គិសនីនេះ នឹងទាក់ទាញវិនិយោគគិនក្នុងស្រុក និងក្រៅស្រុកតាមរយៈមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់។ គ្រប់ការវិនិយោគទាំងអស់ត្រូវការចាំបាច់ណាស់នូវថាមពលអគ្គសនី ដើម្បីប្រើប្រាស់ក្នុងរោងចក្រ ឧស្សាហកម្ម ការិយាល័យ និងតំបន់ទេសចរណ៍ជាដើម។

៦.៤.៥ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

→ ក្រុមហ៊ុននឹងជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការបង់សេវាលើការប្រើប្រាស់អគ្គិសនីរបស់ក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា។

→ សកម្មភាពរបស់ក្រុមហ៊ុនបានបង្កើតនូវទំនាក់ទំនងសេវាកម្មនានា ដល់ក្រុមហ៊ុនផ្សេងៗ ដោយក្រុមហ៊ុនមានទុនវិនិយោគរាប់លានដុល្លាអាមេរិកសម្រាប់អភិវឌ្ឍន៍ ប្រទេសកម្ពុជា។

Draft